
សាសនសុភាសិត
ភាគ ៣
សម្រាប់សាលាធម្មវិន័យ
ថ្នាក់ឯក
INSTITUT BOUDDHIQUE
ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៨

## សេចក្ដីបញ្ជាក់
## ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " សាសនសុភាសិត " សម្រាប់សាលាធម្មវិន័យ ត្រូវបានបោះពុម្ពឡើងវិញ ដោយបានទទួលការឧបត្ថម្ភពីគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (Japan Sotoshu Relief Committee) និងពីអង្គការ រិស្សូ កូសី-កៃ ( Rissho Kosei-Kai) ។

គោលបំណងនៃការបោះពុម្ពឡើងវិញ គឺសំដៅ :

- ផ្ដល់អោយពុទ្ធសាសនិក មានគោលធម៌សម្រាប់ទន្ទេញអោយចាំមាត់ស្ទាត់ជំនាញ,
- រក្សាមតិកវប្បធម៌ អក្សរសាស្ត្រ អោយគង់វង្សឡើងវិញ និងរីកចំរើន,
- ផ្សព្វផ្សាយចំណេះចេះដឹងទូទៅក្នុងពលរដ្ឋកម្ពុជា ។

ពុទ្ធសាសនបណ្ឌិត្យ នឹងចេះតែខិតខំចាត់ការបោះពុម្ព ទាំងសៀវភៅសិក្សា ទាំងសៀវភៅអានគ្រប់បែបយ៉ាង ដែលពុទ្ធសាសនបណ្ឌិត្យពីមុនធ្លាប់មាន ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថផង ដើម្បីរួមចំណែកដល់ការកសាងប្រទេសកម្ពុជា ខាងវិស័យវប្បធម៌ និងអក្សរសាស្ត្រផង ។

សូមឧទ្ទិសសៀវភៅ " សាសនសុភាសិត " នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និងលើកស្ទួយអក្សរសាស្ត្រជាតិ ហើយជាពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរ នៅកម្ពុជា !

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនលូតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេស និងលើកស្ទួយអក្សរសាស្ត្រជាតិ និងព្រះពុទ្ធសាសនា អោយបានរីកចំរើន ជាភិយ្យោភាព តរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន និងអង្គការ រិស្សូ កូសី-កៃ ដែលបានផ្ដល់ការឧបត្ថម្ភយ៉ាងឧត្ដុង្គឧត្ដមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៩៤

ពុទ្ធសាសនបណ្ឌិត្យ

# អារម្ភកថា

សាសនភាសិតភាគ៣នេះ មានសេចក្ដីជ្រាលជ្រៅល្អិតជាងភាគ២ យើងបានដកស្រង់ពីក្នុងអាគតដ្ឋានផ្សេងៗ ដូចមានចង្អុលឈ្មោះគម្ពីរជាភ័ស្ដុតាងស្រាប់ យកមករៀបរៀងឱ្យសមល្មមដល់ឋានៈ នៃអ្នករៀនធម្មថ្នាក់ឯក។ អ្នកសិក្សាធម្ម កាលបើបានទន្ទេញគោលធម៌ទាំងនេះចាំស្ទាត់ហើយ ក៏នឹងអាចយល់សេចក្ដីយ៉ាងច្បាស់លាស់បាន ដោយសារបានស្ដាប់ពាក្យពន្យល់របស់ធម្មាចារ្យ ដែលស្រាវជ្រាវយកសេចក្ដីពិស្ដាររអំពីគម្ពីរផ្សេងៗ មកពន្យល់ ឬក៏ដោយសារអ្នករៀនបានមើលសៀវភៅអធិប្បាយសាសនសុភាសិត ដែលមានសេចក្ដីទូលាយល្មមយល់បាន។

កាលបើអ្នកសិក្សាធម្ម បានរៀនដល់ថ្នាក់ឯកដោយគ្រប់គ្រាន់ហើយនឹងបានជាបណ្ឌិតទាំងផ្លូវធម៌នឹងផ្លូវលោក អាចតាំងខ្លួនឱ្យជាបុគ្គលគួរដល់កិច្ចការយ៉ាងខ្ពង់ខ្ពស់បាន។ បើមានវិរិយភាពមនរួញរាទេ គួរព្យាយាមមើលសៀវភៅ ឬគម្ពីរផ្សេងៗតទៅទៀត ទើបបានទៅជាបណ្ឌិតជាពហុស្សូតយ៉ាងប្រសើរបំផុតក្នុងព្រះពុទ្ធសាសនា។

សូមឱ្យការសិក្សាធម្មវិន័យលូតលាស់ចម្រើនតាមលំដាប់ទៅ!

ថ្ងៃទី៣ ខែកញ្ញា ២៤៨៦. ១៩៥៣

# សាសនសុភាសិត

## ១-អត្តវគ្គ

"ពួកធម៌និយាយអំពីខ្លួន"

**១-អត្តា ហិ អត្តនោ នាថោ កោហិ នាថោ បរោ សិយា អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ៕**

ខ្លួនឯងជាទីពឹងរបស់ខ្លួនឯង អ្នកដទៃដូចម្តេចនឹងគប្បីជាទីពឹងបាន? ព្រោះថាបុគ្គលមានខ្លួនទូន្មានល្អហើយរមែងបានទីពឹងដែលគេបានដោយកម្រ ។

**២- នត្ថិ អត្តសមំ បេមំ នត្ថិ ធញ្ញសមំ ធនំ នត្ថិ បញ្ញាសមា អាភា វុដ្ឋិ វេ បរមា សរា ៕**

សេចក្តីស្រឡាញ់(ដទៃ) ស្មើដោយខ្លួនមិនមាន ទ្រព្យ(ដទៃ) ស្មើដោយស្រូវមិនមាន ពន្លឺ(ដទៃ) ស្មើដោយប្រាជ្ញាមិនមានភ្លៀងហ្នឹងឯងជាស្រះដ៏ឧត្តម ។

**៣- យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ៕**

ទុស្សីលភាពដ៏ក្រៃលែង តែងគ្របសង្កត់នូវអត្តភាពរបស់ អ្នកណាដូចវល្លិ៍មាលុវា[1] តែងរួបរឹតនូវដើមសាលព្រឹក្ស អ្នកនោះឈ្មោះថាធ្វើខ្លួនឱ្យដូចជាចោរ (ឬបច្ចាមិត្រ) ប្រាថ្នាសេចក្តីវិនាស ។

## ២- អប្បមាទវគ្គ

**៤- អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ៕**

[1] មាលុវាសព្ទនេះច្រើនប្រែថា "ព្ទរព្រៃ" ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទ មានស្មារតី មានសីលល្អ មានតម្រិះដំកល់មាំល្អ ចូរថែរក្សាចិត្តរបស់ខ្លួន ។

**៥- អប្បមាទរតា ហោថ សចិត្តមនុរក្ខថ ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ៕**

អ្នកទាំងឡាយចូរជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរថែរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនឡើងចាកភក់ ដូចជាដំរីជាប់ភក់រើខ្លួនឡើង ។

**៦- អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិវា សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ៕**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ទាំងឃើញភ័យក្នុងសេចក្តីប្រមាទផង រមែងដុតសញ្ញោជនៈ ទាំងតូចទាំងធំ(អស់)ទៅដូចភ្លើងឆេះកំញម។

**៧- អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ៕**

ភិក្ខុត្រេកអរក្នុងសេចក្តីមិនប្រមាទទាំងឃើញភ័យក្នុងសេចក្តីប្រមាទផង ជាអ្នកមិនគួរសាបសូន្យ(ឈ្មោះថាមាន) ក្នុងទីជិតនៃព្រះនិព្វានមែនពិត។

**៨- ឯវំ វិហារី សតោ អប្បមត្តោ ភិក្ខុ ចរំ ហិត្វា មមាយិតានិ ជាតិជ្ជរំ សោកបរិទ្ទវញ្ច ឥធេវ វិទ្វា បជហេយ្យ ទុក្ខំ ៕**

ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ មានស្មារតីមិនប្រមាទ ជាអ្នកដឹង លះសេចក្តីប្រកាន់មាំថារបស់អញបានហើយ ត្រាច់ទៅ គប្បីលះជាតិ ជរា សោកៈ បរិទេវៈ នឹងទុក្ខក្នុងលោកនេះបាន ។

**៩- ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

អ្នកមានប្រាជ្ញាគប្បីធ្វើទីពឹងដែលជំនន់ជន់លិចមិនបានដោយសេចក្តី ព្យាយាម ដោយសេចក្តីមិនប្រមាទ ដោយការសង្រួមនឹងដោយការទូន្មានចិត្ត ។

## ៣- កម្មវគ្គ

"ពួកធម៌និយាយអំពីកម្ម"

**១០- ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិចក្ខណោ សុសំវិហិតកម្មន្តោ ស រាជវសតឹ វសេ ។**

អ្នកណាព្យាយាក្នុងវិធានការមិនប្រមាទមាប្រាជ្ញាឃើញប្រច័ក្ស ចាត់ការងារបានរៀបរយ អ្នកនោះគប្បីនៅក្នុងវង្វង់នៃរាជ ការបាន ។

**១១- បាបញ្ចេ បុរិសោកយិរា ន នំ កយិរា បុនប្បុនំ ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្សុច្ចយោ ។**

បើបុរសគប្បីធ្វើបាប មិនគួរធ្វើបាបនោះរឿយៗ មិនគួរធ្វើសេចក្តីពេញចិត្តក្នុងបាននោះ ព្រោះការសន្សំបាប រមែងនាំទុក្ខមកឱ្យ ។

**១២- យោ បុព្វេ កតកល្យាណោ កតត្ថោ នាវពុជ្ឈតិ បច្ឆា កិច្ចេ សមុប្បន្នេ កត្តារំ នាធិគច្ឆតិ ។**

អ្នកណាដែលអ្នកដទៃធ្វើសេចក្តីល្អ ធ្វើប្រយោជន៍ឱ្យក្នុងកាលមុនតែមិនដឹងច្បាស់ (នូវឧបការៈរបស់គេ) កាលបើកិច្ចកើតឡើងខាងក្រោយអ្នកនោះរមែងមិនបានអ្នកជួយធ្វើកិច្ចទេ ។

**១៣- សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ៕**

ពួកសត្វទាំងអស់ រមែងតក់ស្លុតអំពីអាជ្ញា រមែងខ្លាចអំពីសេចក្តីស្លាប់ បុគ្គលធ្វើខ្លួនឱ្យជាឧបមាហើយ មិនគប្បីសម្លាប់ដោយខ្លួនឯងមិនគប្បីប្រើគេឱ្យសម្លាប់(សត្វដទៃ) ឡើយ ។

## ៤- កិលេសវគ្គ

"ពួកធម៌និយាយអំពីកិលេស"

**១៤- អនិច្ចា អទ្ធុវា កាមា ពហុទុក្ខា មហាវិសា អយោគុឡោវ សន្តត្តា អឃមូលា ទុក្ខប្ផលា ៕**

កាមទាំងឡាយមិនទៀងមិនយឺនយូរ មានទុក្ខច្រើនមានពិសច្រើន ជាឫសនៃសេចក្តីលំបាក មានទុក្ខជាផល ដូចជាដុំដែកក្តៅ ។

**១៥- អវិជ្ជាយ និវុតោ លោកោ វេវិច្ឆា នប្បកាសតិ ជប្បាភិលេបនំ ព្រូមិ ទុក្ខមស្ស មហព្ភយំ ៕**

សត្វលោកត្រូវអវិជ្ជាបិទបាំងហើយមិនប្រាកដ ព្រោះសេចក្តីប្រាថ្នាផ្សេងៗ តថាគតពោលសេចក្តីប្រាថ្នាថាជាគ្រឿងលាបលោកឱ្យជាប់ សេចក្តីទុក្ខជាភ័យធំរបស់សត្វលោកនោះៗ ។

**១៦- ឥច្ឆាយ ពជ្ឈតិ លោកោ ឥច្ឆាវិនយាយ មុច្ចតិ ឥច្ឆាយ វិប្បហានេន សព្វំ ឆិន្ទតិ ពន្ធនំ ៕**

សត្វលោករមែងជាប់ដោយសេចក្តីប្រាថ្នា នឹងរួចបានព្រោះកម្ចាត់សេចក្តីប្រាថ្នា ព្រោះលះសេចក្តីប្រាថ្នាចេញ ទើបឈ្មោះថាកាត់ចំណងទាំងពួងបាន ។

**១៧- ឥច្ឆា ចរំ បរិកស្សតិ ឥច្ឆា លោកស្មិ ទុជ្ជហា ឥច្ឆាពទ្ធា បុថូ សត្តា**

**ចាសេនសត្តុណី យថា ១**

សេចក្តីប្រាថ្នាតែងទាញនរជនទៅ សេចក្តីប្រាថ្នាដែលគេលះបង់ដោយលំបាកក្នុងលោក ពួកសត្វជាច្រើនដែលជាប់ដោយសេចក្តីប្រាថ្នាដូចជាមេបក្សីជាប់អន្ទាក់។

**១៨- ឧបេក្ខកោសទាសតោ នលោកេ មញ្ញតិ សមំ នវិសេសី ន នីចេយ្យោ តស្សនា សន្តិឧស្សទា ១**

អ្នកព្រងើយកន្តើយ មានស្មារតីគ្រប់កាល មិនសំគាល់ខ្លួនថាស្មើនឹងគេ ជាពិសេសជាងគេ ក្នុងលោក អ្នកនោះឈ្មោះថាមិនមានកិលេសជាគ្រឿងពូនឡើយង ។

**១៩- ឧច្ឆិន្នភវតណ្ហស្ស សន្តចិត្តស្ស ភិក្ខុនោ វិក្ខីណោ ជាតិសំសារោ នត្ថិតស្ស បុនព្ភវោ ១**

ភិក្ខុណា កាត់ភវតណ្ហាជាដាច់ខាត មានចិត្តស្ងប់ មានការអន្ទោលកើតអស់ហើយ ភិក្ខុនោះរមែងមិនមានភពទៀត ។

**២០- ឯវមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ វីតតណ្ហោ អនាទានោ សតោ ភិក្ខុបរិព្វជេ ១**

ភិក្ខុដឹងទោសយ៉ាងនេះថា "តណ្ហាជាដែនកើតនៃទុក្ខហើយ" គប្បីជាអ្នកប្រាសចាកតណ្ហាមិនប្រកាន់មាំមានស្មារតីវៀរស្រឡះ ។

**២១- កាមា ហិ ចិត្រា មធុរា មនោរមា វិរូបរូបេន មថេន្តិ ចិត្តំ អាទីនវំ កាមគុណេសុ និស្វា ឯកោ ចរេ ខគ្គវិសាណកប្បោ ១**

មែនពិត កាមទាំងឡាយដ៏ត្រកាលមានរសផ្អែម ជាទីរីករាយនៃចិត្តរមែងញាំញីចិត្តដោយសភាពដែលមានរូបប្លែកៗ បុគ្គលឃើញទោសក្នុងកាមគុណហើយ គប្បីត្រាច់ទៅម្នាក់ឯងដូចកុយរមាស ។

**២២- កោធំ ជហេ វិប្បជហេយ្យ មានំ សញ្ញោជនំ សព្វមតិក្កមេយ្យ តន្នាមរូបស្មិមសជ្ជមានំ អកិញ្ចនំ នានុបតន្តិ សង្ហា ។**

បុគ្គលគប្បីលះសេចក្តីក្រោធ គប្បីលះមានះ គប្បីកន្លងសញ្ញោជនៈទាំងអស់ (ព្រោះ) គ្រឿងជំពាក់ទាំងឡាយរមែងមិនជាប់តាមនូវបុគ្គលនោះដែលមិនជំពាក់ មិនមានកង្វាល់ ក្នុងនាមរូប ។

**២៣- កោធំ ជហេ វិប្បជហេយ្យ មានំ សញ្ញោជនំ សព្វមតិក្កមេយ្យ តន្នាមរូបស្មិមសជ្ជមានំ អកិញ្ចនំ នានុបតន្តិ ទុក្ខា ។**

បុគ្គលគប្បីលះសេចក្តីក្រោធ គប្បីលះមានះ គប្បីកន្លងសញ្ញោជនៈទាំងអស់ (ព្រោះ) សេចក្តីទុក្ខរមែងមិនជាប់តាមនូវ បុគ្គលនោះ ដែលមិនជាប់ជំពាក់ មិនមានកង្វល់ ក្នុងនាមរូប ។

**២៤- តណ្ហា ជនេតិ បុរិសំ ចិត្តមស្ស វិធាវតិ សត្តោ សំសារមាបាទិ ទុក្ខា ន បរិមុច្ចតិ ។**

តណ្ហា ញុំាងបុរសឱ្យកើត ចិត្តរបស់បុរសនោះរមែងស្ទុះស្ទា សត្វបានដល់នូវការអន្ទោល(កើតស្លាប់) រមែងមិនរួចផុតចាកទុក្ខទេ ។

**២៥- តណ្ហា ជនេតិ បុរិសំ ចិត្តមស្ស វិធាវតិ សត្តោ សំសារមាបាទិ ទុក្ខមស្ស មហព្ភយំ ។**

តណ្ហាញុំាងបុរសឱ្យកើត ចិត្តរបស់បុរសនោះរមែងស្ទុះស្ទា សត្វបានដល់នូវការអន្ទោល (កើតស្លាប់) ទុក្ខជាភ័យធំរបស់សត្វនោះ ។

**២៦- តណ្ហា ជនេតិ បុរិសំ ចិត្តមស្ស វិធាវតិ សត្តោ សំសារមាបាទិ កម្មំ តស្ស បរាយនំ ។**

តណ្ហាញុំាងបុរសឱ្យកើត ចិត្តរបស់បុរសនោះ រមែងស្ទុះស្ទា សត្វបានដល់នូវ

ការអន្ទោល (កើតស្លាប់) កម្មជាទីប្រព្រឹត្តទៅខាងមុខរបស់សត្វនោះ ។

**២៧- តណ្ហា ខុឱ្ឌិតោលោកោ ជរាយ បរិវារិតោ មច្ចុនាបិហិតោលោកោ ទុក្ខេលោកោ បតិដ្ឋិតោ ។**

លោកដែលតណ្ហាឡើង ដែលជរាឡោមព័ទ្ធ ត្រូវមច្ចុខ្ទប់ទុក តាំងនៅក្នុងសេចក្តីទុក្ខ ។

**២៨- និទ្ទំ តន្ទឹ សហេ ថីនំ បមាទេន ន សំវសេ អតិមានេ ន តិដ្ឋេយ្យ និព្វានមនសោ នរោ ។**

នរជនមានចិត្តបង្អោនទៅក្នុងព្រះនិព្វានគប្បីអត់ទ្រាំនូវការដេកលក់ ការខ្ជិលច្រអូស ការងោកងក់ មិនគប្បីនៅរួមដោយសេចក្តីប្រមាទ មិនគប្បីតាំងនៅក្នុងការមើលងាយ (អ្នកដទៃ) ។

៣០- និរាសត្តី អនាគតេ អតីតំ នានុសោចតិ វិវេកទស្សី ផស្សេសុ ទិដ្ឋីសុ ច ន និយ្យតិ ។

អ្នកមិនសង្ឃឹមក្នុងរបស់ដែលមិនទាន់មកដល់ មិនសោកស្តាយរបស់ដែលកន្លងបាត់ទៅឃើញនូវសេចក្តីស្ងាត់ក្នុងផស្សៈទាំងឡាយឥតអ្នកណាមួយ នាំទៅបានព្រោះទិដ្ឋិទាំងឡាយ ។

**៣១- បុរាណំ នាភិនន្ទេយ្យ នវេ ខន្តិមកុព្វយេ ហិយ្យមានេ នសោចេយ្យអាកាសនសិតោសិយា ។**

មិនគប្បីត្រេកត្រអាលចំពោះរបស់ចាស់ មិនគប្បីធ្វើសេចក្តីល្មមចិត្តក្នុងរបស់ថ្មី កាលរបស់នោះវិនាសទៅក៏មិនគប្បីសោកស្តាយមិនគប្បីអាស្រ័យតណ្ហាឡើយ ។

**៣២- មច្ចុនាព្ភាហតោលោកោ ជរាយ បរិវារិតោ តណ្ហាសល្លេន ឱតិណ្ណោ**

**ឥច្ឆាធុមាយិតោសទា ។**

សត្វលោកត្រូវមច្ចុកម្ចាត់ ត្រូវជរារួបរឹត ត្រូវសរគឺតណ្ហាចាក់ដោត ត្រូវតណ្ហាដុតបំពត់សព្វៗកាល ។

**៣៣- មានុបេតា អយំ បជា មានគន្ថា មានវិនិព្វទ្ធា ទិដ្ឋីសុ ព្យារម្ភកតា សំសារំ នាតិវត្តតិ ។**

ពួកសត្វនេះប្រកបដោយមានះ មានមានះជាគ្រឿងចងស្រេះត្រូវមានះចង់ធ្វាក់ទុក ផ្តើមធ្វើខុសព្រោះទិដ្ឋិ រមែងកន្លងសង្សារទៅមិនបាន ។

**៣៤- មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ អន្ធតំ តទា ហោតិ យំមោហោ សហតេ នរំ ។**

អ្នកវង្វេងរមែងមិនដឹងអត្ថ មិនឃើញធម៌ សេចក្តីវង្វេងរមែងគ្របសង្កត់នរជនក្នុងកាលណា សេចក្តីងងឹតស្លុបក៏មានក្នុងកាលនោះ ។

**៣៥- យស្សនត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ មមត្តំ សោ អសំវិន្ទំ នត្ថិមេតិ ន សោចតិ ។**

អ្នកណាមិនមានកង្វល់ថានេះរបស់អញឬ របស់អ្នកដទៃ អ្នកនោះកាលមិនប្រកាន់ថាជារបស់អញទើបមិនសោកស្តាយថា "របស់អញមិនមាន" ។

**៣៦- យោធ កាមេ អច្ចតរិ សង្គំលោកេ ទុរច្ចយំ នសោសោចតិ នាជ្ឈេតិ ឆិន្នសោតោអពន្ធនោ ។**

អ្នកណាឆ្លងផុតចាកកាម នឹងគ្រឿងជំពាក់ដែលឆ្លងបានដោយលំបាកក្នុងលោកនេះ អ្នកនោះឈ្មោះថាកាត់ខ្សែតណ្ហាបានមិនមានចំណង ទើបមិនសោកស្តាយមិនត្រេកអរ ។

**៣៧- យោ វេ អវិទ្វា ឧបធឹ ករោតិ បុនប្បុនំ ទុក្ខមុបេតិ មន្ទោ តស្មា បជានំ ឧបធឹន កយិរា ទុក្ខស្ស ជាតិប្បភវានុបស្សី ។**

អ្នកណាមិនដឹងរមែងធ្វើនូវឧបធិក្កិលេស អ្នកនោះឈ្មោះថាមនុស្សខ្លៅ រមែងបានសេចក្តីទុក្ខរឿយៗ ព្រោះហេតុនោះ បុគ្គលកាលដឹងច្បាស់ឃើញថា ជាតិជាដែនកើតទុក្ខ មិនគប្បីធ្វើឧបធិឡើយ ។

**៣៨- លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ ។**

អ្នកល្មោភរមែងមិនដឹងអត្ថ មិនឃើញធម៌ សេចក្តីល្មោភរមែងគ្របសង្កត់នរជនក្នុងកាលណា សេចក្តីងងឹតស្លុបរមែងមានក្នុង កាលនោះ ។

**៣៩- វនំ ឆិន្ទថ មា រុក្ខំ វនតោ ជាយតី ភយំ ឆេត្វា វនញ្ច វនថញ្ច និព្វនា ហោថ ភិក្ខវោ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកាត់នូវព្រៃ (គឺកិលេស) កុំកាត់ដើមឈើ ភ័យរមែងកើតអំពីព្រៃ (គឺកិលេស) អ្នកទាំងឡាយចូរកាត់ព្រៃធំនឹងព្រៃតូច(គឺកិលេស) ចេញហើយជាអ្នកមិនមានព្រៃ (គឺកិលេសឡើយ) ។

**៤០- ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ ខន្តិ ពលំ វ យតីនំ ខន្ត ហិតសុខាវហា ។**

ខន្តជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញា ខន្តីជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ ខន្តីជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ ខន្តិជាគុណជាតិនាំមកនូវប្រយោ-ជន៍នឹងសេចក្តីសុខ ។

**៤១- ន សុទ្ធិ សេចនេន អត្ថិ នបិ កេវលីព្រាហ្មណោ ន ចេវ ខន្តិ សោរច្ចះ នបិ សោ បរិនិព្វុតោ ។**

សេចក្តីបរិសុទ្ធក្តីអ្នកដែលប្រសើរសុទ្ធសាធក្តី ខន្តីនឹងសោរច្ចៈក្តីអ្នកដែលត្រជាក់ស្និទ្ធក្តីរមែងមិនមាន ព្រោះការជម្រះលាង(ដោយទឹកឡើយ) ។

**៤២- នហេតមត្ថំ មហតីបិ សេនា សរាជិកា យុជ្ឈ មានា សតេថ យំ ខន្តិមា សប្បុរិសោ លតេថ ខន្តិពលស្សុបសមន្តិ វេរា ។**

សប្បុរសអ្នកមានខន្តី គប្បីបាននូវប្រយោជន៍ណា សេនាដែលមានព្រះរាជា (ជាប្រមុខ) សូម្បីច្រើនក៏ដោយគប្បីច្បាំងយកនូវប្រយោជន៍នោះមិនបានឡើយ (ព្រោះថា) ពៀរទាំងឡាយរបស់សប្បុរសអ្នកមាន ខន្តីជាកម្លាំងរមែងស្ងប់រម្ងាប់ ។

## ៦- ចិត្តវគ្គ

"ពួកធម៌និយាយអំពីចិត្ត"

**៤៣- អនវស្សុតចិត្តស្ស អនន្វាហតចេតសោ បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។**

អ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសៈមិនខ្ទាំងខ្ទប់ មានបុណ្យនឹងបាបបន្សាប់បង់ហើយ ជាអ្នកភ្ញាក់រឭករមែងមិនមានភ័យ ។

**៤៤- កុម្ភូបមំ កាយមិមំ វិទិត្វា នគរូបមំ ចិត្តមិទំ ថបេត្វា យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសនោ សិយា ។**

បុគ្គលដឹងកាយនេះថាមានឧបមាដោយឆ្នាំងហើយបិទចិត្តនវដែល មានឧបមាដោយក្រុង គប្បីច្បាំងនូវមារដោយអាវុធគឺបញ្ញា ទាំងគប្បីរក្សានូវជម្រះមិនគប្បីអាល័យឡើយ ។

**៤៥- ចិត្តេន នីយតិ លោកោចិត្តេន បរិកស្សតិ ចិត្តស្ស ឯកធម្មស្ស សព្វេវ វសមន្វគូ ។**

សត្វលោកដែលចិត្តនាំទៅ ដែលចិត្តទាញកន្ត្រាក់ទៅ សត្វទាំងពួងសុទ្ធតែ

ប្រព្រឹត្តទៅតាមអំណាចនៃធម៌មួយគឺចិត្ត ។

**៤៦- តណ្ហាធិបន្នា វតសីលពន្ធា លូខំ តបំ វស្សសតំ ចរន្តា ចិត្តញ្ច នេសំ ន សម្មា វិមុត្តំ ហីនត្តរូបា ន បារង្គមា តេ ។**

ពួកជនដែលតណ្ហា គ្របសង្កត់ ជាប់ជំពាក់ដោយសីលវ័តប្រព្រឹត្តតប : ដ៏សៅហ្មង អស់រយនៃឆ្នាំ ឯចិត្តរបស់ពួកជាននោះមិនផុតស្រឡះដោយល្អទេ ពួកជននោះមានអត្តភាពដ៏ថោកទាប រមែងមិនដល់នូវត្រើយ គឺនិព្វានឡើយ ។

**៤៧- ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលគេផ្ចញ់ផ្ចាល់បានដោយលំបាក ជាចិត្តស្រាលច្រើនធ្លាក់ទៅក្នុងអារម្មណ៍ដែលគេតែងប្រាថ្នា (យ៉ាងនេះ) ជាការល្អ (ព្រោះថា) ចិត្តដែលគេទូន្មានហើយ នាំសុខមកឱ្យ ។

**៤៨- បនុដ្ឋចិត្តស្ស ន ជាតិ ហោតិ ន ចាបិ នំ ទេវតា បូជយន្តិ យោ ភាតរំ បេត្តិកំ សាបតេយ្យំ អវញ្ចយី ទុក្កដកម្មការី ។**

អ្នកណាធ្វើអំពើអាក្រក់ បោកប្រាស់ទ្រព្យសម្បត្តិជារបស់ប្អូនឬជារបស់មាតាបិតា អ្នកនោះឈ្មោះថាមានចិត្តប្រទូស្ត រមែងមិនមានសេចក្តីចម្រើន ទាំងទេវតាក៏មិនបូជាអ្នកនោះឡើយ ។

**៤៩- ភិក្ខុ សិយា ឈាយិ វិមុត្តចិត្តោ អាកង្ខេ វេ ហទយស្សានុមត្តឹ លោកស្ស ញត្វា ឧទយព្វយញ្ច សុចេតសោ អនិស្សិតោ តទានិសំសោ ។**

ភិក្ខុជាអ្នកមានឈាន មានចិត្តផុតស្រឡះហើយ ដឹងនូវការកើតនឹងការសូន្យទៅនៃលោក ហើយមានចិត្តល្អ ដែលកិលេសអាស្រ័យមិនបានមានធម៌នោះជាអានិ-សង្ស គប្បីប្រាថ្នាសេចក្តីបរិសុទ្ធិនៃចិត្តបាន ។

**៥០- យោ អលីនេន ចិត្តេន អលីនមនសោ នរោ ភាវេតិ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយំ ៕**

នរជនណាមានចិត្តមិនរួញរា មានចិត្តមិនខ្ជិល ចម្រើនកុសលធម៌ដើម្បីការលុះនូវធម៌ដែលក្សេមចាកយោគៈ នរជននោះគប្បីលុះនូវធម៌ជាទីអស់ទៅនៃសំយោជនៈទាំងពួងតាមលំដាប់ ។

**៥១- សុទុទ្ទសំ សុណិបុណំ យត្ថ កាមនិបាតិនំ ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ៕**

អ្នកមានប្រាជ្ញាគប្បីរក្សាចិត្ត ដែលគេឃើញបានដោយលំបាកពេកជាចិត្តល្អិតពេក ច្រើនធ្លាក់ទៅក្នុងអារម្មណ៍ដែលគេតែងប្រាថ្នា (ព្រោះថា) ចិត្តដែលគេគ្រប់គ្រងហើយនាំសុខមកឱ្យ ។

## ៧- ទានវគ្គ

"ពួកធម៌និយាយអំពីទាន"

**៥២- អទេយ្យេសុ អទទំ ទានំ ទេយ្យេសុ យោ បវេច្ឆតិ អាបទាសុ ព្យសនំ បត្តោ សហាយំ អធិគច្ឆតិ ៕**

អ្នកណា មិនឱ្យទានដល់មនុស្សដែលមិនគួរឱ្យ ជួយផ្តល់មនុស្សដែលគួរឱ្យ អ្នកនោះទោះដល់សេចក្តីវិនាស ព្រោះអន្តរាយក៏គង់បាននូវសំឡាញ់ ។

**៥៣- អទេយ្យេសុ ទទំ ទានំ ទេយ្យេសុ នប្បវេច្ឆតិ អាបទាសុ ព្យសនំ បត្តោ សហាយំ នាធិគច្ឆតិ ៕**

អ្នកណាឱ្យទានដល់មនុស្សដែលមិនគួរឱ្យ មិនជួយផ្តល់មនុស្សដែលគួរឱ្យ អ្នកនោះបើដល់សេចក្តីវិនាសព្រោះអន្តរាយ ក៏មិនបាននូវសំឡាញ់ ។

**៥៤- អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ យានទោ**

**សុខទោ ហោតិ ទីបទោ ហោតិចក្ខុទោ ។**

អ្នកឱ្យគ្រឿងស៊ីឈ្មោះថាឱ្យកម្លាំង អ្នកឱ្យសំពត់ឈ្មោះថាឱ្យពណ៌សម្បុរ អ្នកឱ្យយានឈ្មោះថាឱ្យសេចក្តីសុខ អ្នកឱ្យប្រទីបឈ្មោះថាឱ្យចក្ខុ ។

**៥៥- មនាបទាយី លភតេ មនាបំ អគ្គស្ស ទាតា លភតេ បុនគ្គំ វរស្ស ទាតា វរលាភី ច ហោតិ សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ ។**

អ្នកឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្ត អ្នកឱ្យរបស់ដ៏លើសរមែងបានរបស់ដ៏លើស អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អ អ្នកឱ្យរបស់ប្រសើរ រមែងចូលទៅដល់ទីឋានប្រសើរ ។

## ៨- ធម្មវគ្គ

"ពួកធម៌និយាយអំពីធម៌"

**៥៦- អត្ថង្គតស្ស ន បមាណមត្ថិ យេន នំ វជ្ជុ តំ តស្ស នត្ថិ សព្វេសុ ធម្មេសុ សមូហតេសុ សមូហតា វាទបថាបិ សព្វេ ។**

លោកអ្នករំលត់ខន្ធទៅហើយរមែងមិនមានប្រមាណ ពួកជនគប្បីពោលនូវលោកដោយហេតុណា ហេតុនោះមិនមានដល់លោកឡើយ កាលបើធម៌ទាំងពួងដែលលោកដកឡើងហើយ សូម្បីគន្លងពាក្យពោលក៏លោកដកឡើងហើយទាំងអស់ ។

**៥៧- អាទានតណ្ហំ វិនយេថ សព្វំ ឧទ្ធំ អធោ តិរិយំ វាបិ មជ្ឈេ យំ យំ ហិ លោកស្មិំ ឧបាទិយន្តិ តេនេវ មារោ អន្វេតិ ជន្តុំ ។**

គប្បីកំចាត់តណ្ហាដែលជាហេតុប្រកាន់មាំទាំងអស់ ទាំងខាងលើខាងក្រោមទទឹង នឹងកណ្តាល ព្រោះថាពួកសត្វប្រកាន់មាំរបស់ណា ឬក្នុងលោកព្រោះរបស់នោះៗឯងមាររមែងជាប់តាមសត្វទៅ ។

**៥៨- ឧច្ឆិន្ទ សិនេហមត្តនោ កុមុទំ សារទិកំវ បាណិនា សន្តិមគ្គមេវ**

**ព្រូហយ និព្វានំ សុគតេន ទេសិតំ ។**

ចូរដកឡើងនូវសេចក្ដីស្រឡាញ់របស់ខ្លួន ដូចគេដកឈូកដែលកើតក្នុងសរទកាលដោយដៃដូច្នោះ ចូរចម្រើននូវផ្លូវនៃសេចក្ដីស្ងប់តែម្យ៉ាង ព្រោះថាព្រះនិព្វានគឺព្រះសុគតសម្ដែងទុកហើយ ។

**៥៩- ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។**

គួរទូន្មានគួរប្រៀនប្រដៅទាំងគួរហាមឃាត់ចាកធម៌របស់អសប្បុរស ព្រោះថាអ្នកទូន្មានប្រៀនប្រដៅនោះរមែងជាទីស្រឡាញ់នៃពួកសប្បុរសតែមិនជាទី ស្រឡាញ់នៃពួកអសប្បុរសឡើយ ។

**៦០- កាមេសុ ព្រហ្មចរិយវា វីតតណ្ហោ សទា សតោ សង្ខាយ និព្វុតោ ភិក្ខុ តស្ស នោ សន្តិ ឥញ្ជិតា ។**

ភិក្ខុអ្នកមានព្រហ្មចរិយធម៌ប្រាសចាកតណ្ហា មានស្មារតីសព្វកាល ពិចារណាហើយត្រជាក់ចិត្ត ភិក្ខុនោះរមែងមិនមានសេចក្ដីញាប់ញ័រ ក្នុងកាមទាំងឡាយឡើយ។

**៦១- ខត្តិយោ ច អធម្មដ្ឋោ វេស្សោ ចាធម្មនិស្សិតោ តេ បរិច្ចជ្ជុតោ លោកេ ឧបបជ្ជន្តិ ទុគ្គតឹ ។**

ក្សត្រមិនតាំងនៅក្នុងធម៌ក្ដី វេស្សៈមិនអាស្រ័យនូវធម៌ក្ដី ជនទាំងពីរនោះលះលោកហើយ រមែងចូលដល់ទុគ្គតិ ។

**៦២- គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។**

អ្នកមានផ្លូវឆ្ងាយដល់ហើយ ប្រាសចាកសេចក្ដីសោក ផុតស្រឡះក្នុងធម៌ទាំងពួង លះបង់កិលេសជាគ្រឿងចងស្រេះទាំងអស់ រមែងមិនមានសេចក្ដីក្ដៅក្រហាយ ។

**៦៣- ចជេ ធនំ អង្គវរស្ស ហេតុ អង្គំ ចជេ ជីវិតំ រក្ខមានោ អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ ចជេ នរោ ធម្មមនុស្សរន្តោ ៕**

នរជនគប្បីលះទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលរក្សាជីវិតគប្បីលះអវយវៈ កាលរលឹកឃើញធម៌គប្បីលះអវយវៈ ទ្រព្យនឹងជីវិតទាំងអស់ ។

**៦៤- ឆន្ទជាតោ អនក្ខាតេ មនសា ច ផុដោ សិយា កាមេ ច អប្បដិពន្ធចិត្តោ ឧទ្ធំសោតោតិ វុច្ចតិ ៕**

គប្បីជាអ្នកមានសេចក្ដីពេញចិត្ត ទាំងចងចិត្តទុកក្នុងព្រះនិព្វានដែលអ្នកណាប្រាប់គ្នាមិនបាន ព្រោះថាអ្នកមិនមានចិត្តប្រតិព័ទ្ធក្នុងកាមលោកហៅថា អ្នកមានខ្សែក្នុងខាងលើ ។

**៦៥- ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុខា[2] ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ ៕**

សេចក្ដីស្រេកឃ្លានជារោគយ៉ាងក្រៃលែង សង្ខារជាទុក្ខយ៉ាងក្រៃលែង ការដឹងដំណើរនេះតាមពិតហើយ រលត់ទុក្ខបាន ជាសុខយ៉ាងក្រៃលែង ។

**៦៦- ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ សតញ្ច ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ ៕**

រាជរថដែលគេវិចិត្រល្អហើយ រមែងគ្រាំគ្រាសូម្បីសរីរៈក៏គង់ចូលដល់ជរាដែរ ចំណែកធម៌របស់ពួកសប្បុរសមិនចូលដល់ជរាទេ ពួកសប្បុរសនិងពួកសប្បុរស រមែងដឹងគ្នាយ៉ាងនេះឯង ។

**៦៧- តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា ផុសន្តិធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ៕**

---

[2] បាលីនេះតាមសំយោគវិធានជាទុក្ខា ប៉ុន្តែក្នុងទីនេះបានជាលោកមិនតម្រូតព្រោះរក្សាសម្ពស្សឆន្ទ ។

អ្នកប្រាជ្ញទាំងនោះ មានសេចក្ដីពិនិត្យ មានព្យាយាមរឿយៗមានសេចក្ដីប្រឹងប្រែងមាំទាំងជានិច្ច រមែងពាល់ត្រូវព្រះនិព្វានដែលក្សេមចាកយោគៈ មិនមានធម៌ដទៃក្រៃលែងជាង ។

**៦៨- ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ ច នាញ្ញត្រ ទុក្ខា សម្ភោតិ នាញ្ញត្រ ទុក្ខា និរុជ្ឈតិ ។**

ទុក្ខហ្នឹងឯង រមែងកើតឡើង ទុក្ខរមែងតាំងនៅផង សាបសូន្យទៅផង ក្រៅអំពីទុក្ខមិនមានអ្វីកើត ក្រៅអំពីទុក្ខមិនមានអ្វីរលត់ ។

**៦៩- ធម្មោ បថោ មហារាជ អធម្មោ បន ឧប្បថោ អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគ្គតឹ ។**

បពិត្រមហារាជ ព្រះធម៌ជាផ្លូវ(គួរដើរតាម) ចំណែកអធម៌ជាផ្លូវខុស(មិនគួរដើរតាម) អធម៌រមែងនាំទៅកាន់នរក ព្រះធម៌រមែងឱ្យដល់នូវសុគតិ ។

**៧០- នន្ទិសញ្ញោជនោ លោកោ វិតក្កស្ស វិចារណា តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។**

សត្វលោកមានសេចក្ដីត្រេកត្រអាល ជាគ្រឿងចងក្រៀកជាទីត្រាច់ទៅនៃវិតក្កៈ លោកពោលថា និព្វានព្រោះការលះតណ្ហាចេញបាន ។

**៧១- នាញ្ញត្រពោជ្ឈា តបសា នាញ្ញត្រ ឥន្ទ្រិយសំវរា នាញ្ញត្រ សព្វនិស្សគ្គា សោត្ថឹ បស្សាមិ បាណិនំ ។**

តថាគតមិនឃើញសួស្ដីរបស់សត្វទាំងឡាយ ក្រៅអំពីបញ្ញា ក្រៅអំពីសេចក្ដីព្យាយាម ក្រៅអំពីការសង្រួមឥន្ទ្រិយ៍ នឹងការលះបង់ឡើយ ។

**៧២- បញ្ចក្ខន្ធា បរិញ្ញាតា តិដ្ឋន្តិ ឆិន្នមូលកា ទុក្ខក្ខយោ អនុប្បត្តោ នត្ថិទានិ**

**ចុនព្ភោ ៗ**

ខន្ធទាំង៥ ដែលអ្នកណាកំណត់ដឹងហើយ មានឫសកាត់ដាច់ហើយតាំងនៅបាន ធម៌ជាទីអស់ទុក្ខដែលអ្នកនោះដល់ហើយ ឥឡូវនេះមិនមានភពតទៅទៀត ។

**៧៣- បត្តា តេ និព្វានំ យេ សុត្តា ទសពលស្ស សាសនេ អប្បោស្សុក្កា ឃដេន្តិ ជាតិមរណប្បហានាយ ៗ**

អ្នកណាប្រកបក្នុងធម៌វិន័យ របស់ព្រះទសពល មានសេចក្តីខ្វល់ខ្វាយតិចព្យាយាមដើម្បីលះជាតិនឹងមរណៈអ្នកនោះរមែងលុះព្រះនិព្វាន ។

៧៤- ពហុស្សុតំ ឧបាសេយ្យ សុតញ្ចនវិនាសយេ តំ មូលំ ព្រហ្មចរិយស្ស តស្មា ធម្មធរោ សិយា ។

គប្បីអង្គុយជិតបុគ្គលជាពហូសូត្រ ទាំងមិនគប្បីធ្វើសុតៈឱ្យវិនាស សុតៈនោះជាឫសនៃព្រហ្មចរិយៈ ព្រោះហេតុនោះ គួរជាអ្នកទ្រទ្រង់ធម៌ ។

**៧៥- មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមា ៗ**

បណ្តាផ្លូវទាំងឡាយ ផ្លូវប្រកបដោយអង្គ៨ប្រសើរបំផុត បណ្តាសច្ចៈទាំងឡាយចំណែកសច្ចៈ៤ប្រសើរបំផុត បណ្តាធម៌ទាំងឡាយវិរាគធម៌ប្រសើរបំផុត បណ្តាសត្វទ្វេបាទទាំងឡាយ ព្រះពុទ្ធមានចក្ខុប្រសើរបំផុត ។

**៧៦- យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ ៗ**

នាមនឹងរូបរមែងរលត់ទៅមិនសល់នៅក្នុងទីណា នាមនឹងរូបនោះ រមែងរលត់ក្នុងទីនោះ ព្រោះសេចក្តីរលត់ទៅនៃវិញ្ញាណ ។

**៧៧- យម្ហិ សច្ចញ្ចធម្មោច អហឹសា សញ្ញមោ ទមោ ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ ។**

សច្ចៈ១ ធម្មៈ១ អហឹសា១ សញ្ញមៈ១ ទមៈ១ មាននៅក្នុងបុគ្គលណាព្រះអរិយៈទាំងឡាយតែងសេពនូវបុគ្គលនោះ ធម៌ទាំង៥នេះហៅថាអនាមតធម៌(ធម៌មិនស្លាប់) ក្នុងលោក ។

**៧៨- យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ សោតានំ សំវរំព្រូមិ បញ្ញាយេតេ បិធិយ្យរេ ។**

ខ្សែតណ្ហាណាមាននៅក្នុងលោក សតិជាគ្រឿងរារាំងនូវខ្សែតណ្ហានោះតថាគតពោលថា សតិជាគ្រឿងបិទខ្សែតណ្ហា ខ្សែតណ្ហាទាំងនោះបុគ្គលតែងបិទបានដោយបញ្ញា ។

**៧៩- យេ សន្តចិត្តា និបកា សតិមន្តោ ច ឈាយិនោ សម្មា ធម្មំ វិបស្សន្តិ កាមេសុ អនបេក្ខិនោ ។**

ពួកជនណា មានចិត្តស្ងប់ មានបញ្ញាជាគ្រឿងរក្សាខ្លួន មានសតិមានប្រក្រតីពិនិត្យ មិនអាឡោះអាល័យក្នុងកាមទាំងឡាយ ពួកជននោះរមែងឃើញធម៌ដោយប្រពៃ ។

**៨០- យោ ច បបញ្ចំ ហិត្វាន និប្បបញ្ចបថេ រតោ អារាធយិ សោ និព្វានំ យោគក្ខេមំ អនុត្តរំ ។**

អ្នកណាមួយលះបង់ផ្លូវដែលជាដំណើរយឺតយូរ ត្រេកអរក្នុងផ្លូវដែលមិនមានដំណើរយឺតយូរ អ្នកនោះឈ្មោះថាត្រេកអរនូវព្រះនិព្វានដែលក្សេមចាកយោគៈ មិនមានធម៌ដទៃក្រៃលែងជាង ។

**៨១- សកំ ហិ ធម្មំ បរិបុណ្ណមាហុ អញ្ញស្ស ធម្មំ បន ហីនមាហុ ឯវម្បិ វិគ្គយ្ហ**

**វិវាទយន្តិ សកំ សកំ សម្មតិមាហុ សច្ចំ ។**

សមណព្រាហ្មណ៍ពួកខ្លះ ពោលនូវធម៌របស់ខ្លួនថាបរិបូណ៌ តែពោលនូវធម៌របស់អ្នកដទៃថា ខ្វះខាត ពោលការសន្មតរបស់ខ្លួនៗថា ទៀងទាត់ សមណព្រាហ្មណ៍ពួកនោះរមែងប្រកាន់ខុសគ្នា វិវាទគ្នាដោយហេតុយ៉ាងនេះឯង ។

**៨២- សម្មប្បធានសម្បន្នោ សតិប្បដ្ឋានគោចរោ វិមុត្តិកុសុមសញ្ឆន្នោ បរិនិព្វាយិស្សត្យនាសវោ ។**

អ្នកបរិបូណ៍ដោយសម្មប្បធាន មានសតិប្បដ្ឋានជាអារម្មណ៍ ដ៏ដេរដាសដោយផ្កាគឺវិមុត្តិមិនមានអាសវៈឡើយ នឹងបរិនិព្វាន ។

**៨៣- សុសុខំ វត និព្វានំ សម្មាស ម្ពុទ្ធទេសិតំ អសោកំ វិរជំ ខេម យត្ថ ទុក្ខំ និរុជ្ឈតិ ។**

សេចក្តីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងហើយ មិនមានសោក ប្រាសចាកធូលីក្សេម ឈ្មោះថាសុខប្រពៃមែនពិត ។

**៨៤- សោរច្ចំ អវិហឹសា ច បាទា នាគស្ស តេ ទុប សតិ ច សម្បជញ្ញញ្ច ចរណា នាគស្សតេ បរេ ។**

សោរច្ច នឹងអវិហឹសានោះ ជាជើង (ក្រោយ) ទាំងពីររបស់ស្តេចដំរីសតិនឹងសម្បជញ្ញៈនោះ ជាជើងមុខរបស់ស្តេចដំរី ។

**៨៥- ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ មិច្ឆាទិដ្ឋិ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

មិនគួរសេពធម៌ថោកទាប មិននៅរួមដោយសេចក្តីប្រមាទ មិនគួរសេពមច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

**៨៦- ហីនេន ព្រហ្មចរិយេន ខត្តិយេ ឧបបជ្ជតិ មជ្ឈិមេន ច ទេវត្តំ ឧត្តមេន វិសុជ្ឈតិ ៕**

បុគ្គលរមែងចូលទៅដល់នូវភាពនៃខ្លួនជាក្សត្រ ដោយព្រហ្មចរិយធម៌យ៉ាងទាប ដល់នូវភាពនៃខ្លួនជាទេវតា ដោយព្រហ្មចរិយធម៌យ៉ាងកណ្តាល រមែងបរិសុទ្ធដោយព្រហ្មចរិយធម៌យ៉ាងខ្ពស់ ។

## ៩- បកិណ្ណកវគ្គ

"ពួកធម៌រាយរង"

**៨៧- អចិន្តិតម្បិ ភវតិ ចិន្តិតម្បិ វិនស្សតិ ន ហិ ចិន្តាមយា ភោគា ឥត្ថិយា បុរិសស្ស វា ៕**

របស់ដែលមិនបានគិតទុករមែងកើតមាន របស់ដែលគិតទុកគង់វិនាសបាន ភោគៈ ទាំងឡាយរបស់ស្រ្តីឬបុរសមិនមែនសុទ្ធតែសម្រេចដោយការគិតទេ ។

**៨៨- អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ ឯវំសតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ ៕**

បុគ្គលណាមិនត្រេកត្រអាលចំពោះវេទនា ទាំងខាងក្នុងទាំងខាងក្រៅ មានសតិត្រាច់ទៅយ៉ាងនេះ វិញ្ញាណរមែងរលត់ ។

**៨៩- អជ្ឈត្តមេវ ឧបសមេ នាញ្ញតោ ភិក្ខុ សន្តិមេសេយ្យ អជ្ឈត្តំ ឧបសន្តស្ស នត្ថិ អត្តំ កុតោ និរត្តំ វា ៕**

ភិក្ខុគប្បីរម្ងាប់កិលេសនឹងបាបធម៌ខាងក្នុងចេញ មិនគប្បីស្វែងរកសេចក្តីស្ងប់អំពីទីដទៃ កាលរម្ងាប់ខាងក្នុងបានហើយ សស្សតទិដ្ឋិរមែងមិនមាន ឧច្ឆេទទិដ្ឋិនឹងមានអំពីណា?

**៩០- អប្បស្សាទា ទុក្ខា កាមា នត្ថិ កាមា បរំ ទុក្ខំ យេ កាមេ បដិសេវន្តិ**

**និរយន្តេ ឧបបជ្ជរេ ៕**

កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន ទុក្ខដទៃ ក្រៅអំពីកាមមិនមាន អ្នកណាសេពកាម អ្នកនោះរមែងចូលដល់នរក ។

**៩១- អព្យាបជ្ឈោ សិយា ឯវំ សច្ចវាទី ច មាណវោ អស្មា លោកា បរំលោកំ ឯវំ បេច្ច ន សោចតិ ៕**

មាណពគប្បីជាអ្នកមិនបៀតបៀន ទាំងពោលពាក្យសច្ចៈយ៉ាងនេះ លុះទៅអំពីលោកនេះ ទៅកាន់លោកដទៃហើយ រមែងមិនសោយសោកយ៉ាងនេះ ។

**៩២- អលសោ គិហី កាមភោគី ន សាធុ អសញ្ញតោ បព្វជិតោ ន សាធុ រាជា ន សាធុ អនិសម្មការី យោ បណ្ឌិតោ កោធនោ តំ ន សាធុ ៕**

គ្រហស្ថអ្នកបរិភោគកាមជាអ្នកខ្ជិលច្រអូស មិនល្អ បព្វជិតមិនសង្រួម មិនល្អ ព្រះរាជាមិនពិចារណារួចសឹមធ្វើមិនល្អ បណ្ឌិតដែលមានសេចក្តីក្រោធនោះក៏មិនល្អ ។

**៩៣- អសារេ សារមតិនោ សារេ ចាសារទស្សិនោ តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ៕**

ពួកជនណាមានយោបល់ជាប្រក្រតីថា មានខ្លឹមក្នុងធម៌មិនមានខ្លឹមផង មានប្រក្រតីយល់ឃើញថាមិនមានខ្លឹម ក្នុងធម៌មិនមានខ្លឹមផង ពួកជននោះឈ្មោះថាមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌មានខ្លឹម ។

**៩៤- អតីតំ នានុសោចន្តិ នប្បជប្បន្តិ នាគតំ បច្ចុប្បន្នេន យាបេន្តិ តេន វណ្ណោ បសីទតិ ៕**

បុគ្គលមិនសោកស្តាយ របស់ដែលកន្លងទៅហើយ មិនប្រាថ្នារបស់ដែលមិនទាន់មកដល់ ញ៉ាំងជីវិតឱ្យប្រព្រឹត្តទៅដោយរបស់ដែលកើតឡើងចំពោះមុខ ព្រោះ

ហេតុនោះ ពណ៌សម្បុររមែងស្រស់បស់ ។

**៩៥- អនវដ្ឋិតចិត្តស្ស លហុចិត្តស្ស ទុព្ភិនោ និច្ចំ អទ្ធុវសីលស្ស សុខភាវោ ន វិជ្ជតិ ។**

សុខភាពរមែងមិនមាន ដល់អ្នកដែលមានចិត្តមិនតាំងមាំ មានចិត្តស្រាល ទ្រុស្តមិត្រ មានប្រក្រតីមិនទៀងទាត់ជានិច្ច ។

**៩៦- ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោនរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

នរជនណាជាអ្នកលេងស្រី លេងស្រា លេងល្បែងភ្នាល់បំផ្លាញទ្រព្យដែលខ្លួនបានហើយៗ ការណ៍នោះ (របស់នរជននោះ) ជាប្រធាននៃសេចក្តីវិនាស ។

**៩៧- ឥត្ថី មលំ ព្រហ្មចរិយស្ស ឯត្ថាយំ សជ្ជតេ បជា តបោ ច ព្រហ្មចរិយញ្ច តំ សិនានមនោទកំ ។**

ស្ត្រីជាមន្ទិលរបស់ព្រហ្មចរិយៈ ពួកសត្វនេះតែជាប់ក្នុងស្ត្រីនុ៎ះ តបៈនឹងព្រហ្មចរិយៈ ជាគ្រឿងលាងជម្រះ នូវមន្ទិលនោះមិនបាច់មានទឹក ។

**៩៨- ឧបនីយតិ ជីវិតមប្បមាយុំ ជរូបនីតស្ស ន សន្តិ តាណា ឯតំ ភយំ មរណេ បេក្ខមានោ លោកាមិសំ បជហេ សន្តិបេក្ខោ ។**

ជីវិតគឺអាយុមានប្រមាណតិច ត្រូវជរានាំចូលមកជិត កាលសត្វដែលជរានាំចូលមកជិតហើយ រមែងមិនមានទីពឹងពួនឡើយ បុគ្គលកាលសំឡឹងឃើញភ័យក្នុងមរណៈនោះ ប្រាថ្នានូវសេចក្តីស្ងប់ គប្បីលះបង់នូវលោកាមិសៈចេញ ។

**៩៩- ឧបសន្តោ ឧបរតោ មន្តភាណី អនុទ្ធតោ ធុនាតិ បាបកេ ធម្មេ ទុមបត្តំវ មាលុតោ ។**

អ្នកស្ងប់រម្ងាប់វៀរ(បាប) ប្រសប់និយាយ មិនរន្ធត់ រមែងកំចាត់បងនូវបាបធម៌ បាន ដូចខ្យល់បក់កម្ចាត់ស្លឹកឈើដូច្នោះដែរ ។

**១០០- ឯវញ្ចេ សត្តា ជានេយ្យុំ ទុក្ខាយំ ជាតិសម្ភវោ ន បាណោបាណិនំ ហញ្ញេ បាណឃាតី ហិ សោចតិ ។**

បើសត្វទាំងឡាយ គប្បីដឹងយ៉ាងនេះ ជាតិសម្ភពនេះជាទុក្ខ សត្វមិនគប្បី សម្លាប់សត្វឡើយ ព្រោះថាអ្នកសម្លាប់ រមែងសោយសោក ។

**១០១- កាមេសុ នាភិគិជ្ឈេយ្យ មនសានាវិលោ សិយា កុសលោ សព្វធម្មានំ សតោ ភិក្ខុ បរិព្វជេ ។**

ភិក្ខុមិនគួរជាប់ស្អិតក្នុងកាមទាំងឡាយគួជាអ្នកមានចិត្តមិនកករល្អក់ ជាអ្នក ឈ្លាសក្នុងធម៌ទាំងពួង មានសតិវៀរស្រឡះ ។

**១០២- តនិឯតានិ ទិដ្ឋានិ ភវនេត្តិ សមូហតា ឧច្ឆិន្នំ មូលំ ទុក្ខស្ស នត្ថិទានិ បុនព្ភវោ ។**

អរិយសច្ចទាំងនេះដែលគេឃើញហើយ តណ្ហាអ្នកនាំទៅកាន់ភព ដែលគេដក បានហើយ ឫសនៃទុក្ខដែលគេកាត់ផ្តាច់បានហើយ ឥឡូវនេះ រមែងមិនមានភពតទៅ ទៀត ។

**១០៣- ទានេន សមចរិយាយ សំយមេន ទមេន ច យំ កត្វា សុខិតោ ហោតិ ន ច បច្ឆានុតប្បតិ ។**

បុគ្គលណាធ្វើកម្មណាដោយការឱ្យ ការប្រព្រឹត្តស្មើ ការសង្រួមនឹងការទូន្មាន រមែងជាអ្នកដល់នូវសេចក្តីសុខ ព្រោះកម្មនោះ មិនតាមដុតក្នុងកាលជាខាងក្រោយ ។

**១០៤- និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ អលសោ**

**ភោជបញ្ញាណោ តំ បរាភវតោ មុខំ ។**

នរជនណាដែលដេកច្រើន ហៃប្រជុំនិយាយលេង មិនមានសេចក្តីប្រឹងប្រែង ខ្ជិលច្រអូស មានសេចក្តីក្រោធជាគ្រឿងប្រាកដ គឺឆាប់ខឹងហេតុនោះ (របស់នរជននោះ) ជាប្រធាននៃបុគ្គលអ្នកមានសេចក្តីវិនាស ។

**១០៥- ធជោ រថស្ស បញ្ញាណំ ធូមោ បញ្ញាណមគ្គិនោ រាជា រដ្ឋស្ស បញ្ញាណំ ភត្តា បញ្ញាណមិត្ថិយា ។**

ទង់ជ័យជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រះរាជាគ្រឿងប្រាកដរបស់រដ្ឋ ភស្តា[3] ជាគ្រឿងប្រាកដរបស់ស្ត្រី ។

**១០៦- ធម្មារាមោ ធម្មរតោ ធម្មំ អនុវិចិន្តយំ ធម្មំ អនុស្សរំ ភិក្ខុ សទ្ធម្មា ន បរិហាយតិ ។**

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ កាលសន្សំធម៌ទាំងរលឹកនូវធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។

**១០៧- នត្ថិលោកេរហោនាម បាបកម្មំ បកុព្វតោ បស្សន្តិ វនភូតានិ តំពាលោ មញ្ញតេ រហោ ។**

ឈ្មោះថាទីស្ងាត់របស់អ្នកធ្វើនូវបាបកម្មមិនមានក្នុងលោក ជនពាលរមែងសំគាល់ស្ថានទីជាព្រៃដែលគេឃើញនោះ ថាជាទីស្ងាត់ ។

**១០៨- ន មានកាមស្ស ទមោ ឥធត្ថិ ន មោនមត្ថិ អសមាហិតស្ស ឯកោ អរញ្ញេ វិហរម្បមត្តោ ន មច្ចុធេយ្យស្ស តរេយ្យ បារំ ។**

ក្នុងលោកនេះ អ្នកស្រឡាញ់មានះ រមែងមិនមានការទូន្មានខ្លួន អ្នកមានចិត្តមិនដំកល់មាំ រមែងមិនមានសេចក្តីដឹង អ្នកប្រមាទសូម្បីនៅក្នុងព្រៃម្នាក់ឯង ក៏មិនគប្បីឆ្លង

[3] ភាស់-ស្តា(ជើងដ) ស្វាមី (ប្តី)។

នូវត្រើយនៃដែនម្រឹត្យុបានឡើយ ។

**១០៩- ន បរេសំ វិលោមានិ ន បរេសំ កតាកតំ អត្តនោ វ អវេក្ខេយ្យ កតានិ អកតានិ ច ។**

មិនគួរធ្វើទុកក្នុងចិត្ត នូវពាក្យមួលបង្កាច់របស់អ្នកដទៃ មិនគួរឃ្លាំមើលអំពើដែលអ្នកដទៃធ្វើហើយ ឬ មិនទាន់ហើយ គួរពិចារណាមើលតែអំពើដែលខ្លួនធ្វើហើយ ឬមិនទាន់បានធ្វើប៉ុណ្ណោះ ។

**១១០- បមាទំ ភយតោទិស្វា អប្បមាទញ្ច ខេមតោ ភាវេថដ្ឋង្គិកំ មគ្គំ ឯសាពុទ្ធានុសាសនី ។**

ឃើញសេចក្ដីប្រមាទជាភ័យ ទាំងឃើញសេចក្ដីមិនប្រមាទថាក្សេម(ចាកភ័យ) ហើយគប្បីចម្រើនមគ្គមានអង្គ៨ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

**១១១- បិយានំអទស្សនំ ទុក្ខំ អប្បិយានញ្ច ទស្សនំ តស្មា បិយំ ន កយិរាថ បិយាបាយោ ហិ បាបកោ ។**

ការមិនប្រទះឃើញអារម្មណ៍ជាទីស្រឡាញ់ រមែងជាទុក្ខ ទាំងការប្រទះឃើញអារម្មណ៍ មិនជាទីស្រឡាញ់ក៏ជាទុក្ខដែរ ហេតុនោះមិនគួរធ្វើអារម្មណ៍ឱ្យជាទីស្រឡាញ់ ព្រោះថាការព្រាត់ប្រាសចាកអារម្មណ៍ជាទីស្រឡាញ់ ជាការលាមក ។

**១១២- មច្ចុនាព្ភាហតោ លោកោ បរិក្ខិតោ ជរាយ ច ហញ្ញតិ និច្ចមត្តាណោ បត្តទណ្ឌោវតក្ករោ ។**

សត្វលោកត្រូវមច្ចុកម្ចាត់បង់ ទាំងត្រូវជរារួបរឹត មិនមានទីពឹងពួន រមែងក្ដៅក្រហាយជានិច្ចដូចមនុស្សត្រូវទោសធ្វើតាមអាជ្ញាដូច្នោះឯង ។

**១១៣- យំ លភតិ ន តេន តុស្សតិ យំ បត្ថេតិ លទ្ធំ ហីឡេតិ ឥច្ឆា ហិ**

**អនន្តគោចរា វិគតិច្ឆានំ នមោ គរោម សេ ។**

បុគ្គលបានរបស់ណា មិនត្រេកអរដោយរបស់នោះប្រាថ្នារបស់ណារមែងមើលងាយរបស់ដែលបានហើយនោះ ព្រោះថាសេចក្ដីប្រាថ្នាមានអារម្មណ៍មិនមានទីបំផុត ហ៍ពួកយើងចូរធ្វើនមស្ការ ចំពោះលោកអ្នកប្រាសចាកសេចក្ដីប្រាថ្នា !

**១១៤- យថា ហិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោតិ សម្មតិ ។**

សំឡេងថារថ រមែងមាន ព្រោះផ្សំដោយអង្គយ៉ាងណា កាលខន្ធទាំងឡាយមាននៅឡើយ ការសន្មតិថាសត្វ រមែងមាន ក៏យ៉ាងនោះដែរ ។

**១១៥- យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ ឯវម្បិ តណ្ហានុសយេ អនូហតេ និព្វត្តតិ ទុក្ខមិទំ បុនប្បុនំ ។**

ដើមឈើ កាលដែលឫសនៅមាំទាំ មិនទាន់មានសេចក្ដីអន្តរាយសូម្បីគេកាត់ហើយក៏គង់ដុះឡើងទៀតបានយ៉ាងណាមិញ សេចក្ដីទុក្ខកាលតណ្ហានុស័យ ដែលគេមិនទាន់កម្ចាត់បង់បានរមែងកើតរឿយៗ ក៏យ៉ាងនោះដែរ ។

**១១៦- យស្ស រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា សោ ឥមំ សមុទ្ទំ សគាហំ សរក្ខសំ សឩម្មិភយំ សុទុត្តរំ អច្ចតរិ ។**

រាគៈទោសៈនឹងអវិជ្ជា ដែលអ្នកណាកម្ចាត់បង់ហើយ អ្នកនោះឈ្មោះថា បានឆ្លងនូវសមុទ្រនេះ ដែលមានគ្រោះមានអារ័ក្សទឹក ព្រមទាំងភ័យដែលកើតអំពីរលកដែលគេឆ្លងបានដោយកម្រក្រៃពេក ។

**១១៧- យស្មិំ កាមា ន វសន្តិ តណ្ហា យស្ស ន វិជ្ជតិ កថង្កថា ច យោ តិណ្ណោ វិមោក្ខោតស្សនាបរោ ។**

កាមទាំងឡាយមិនជាប់ក្នុងអ្នកណា តណ្ហាមិនមានដល់អ្នកណា ពុំនោះសោត

អ្នកណាឆ្លងចាកសេចក្ដីសង្ស័យបានហើយ អ្នកនោះ រមែងមានការរួចស្រឡះ មិនមានធម៌ដទៃឡើយ ។

**១១៨- យោ ទុក្ខមទ្ទក្ខិ យតោនិទានំ កាមេសុ សោ ជន្តុ កថំ នមេយ្យ ឧបធី វិទិត្វា សង្គោតិ លោកេ តស្សេវ ជន្តុ វិនយាយ សិក្ខេ ។**

ជនណាបានឃើញទុក្ខ ដែលមានកាមជាហេតុ ជននោះគប្បីបង្អោនចិត្តទៅក្នុងកាមទាំងឡាយដូចម្ដេចបាន ជនដឹងនូវឧបធិថាជាគ្រឿងជាប់ជំពាក់ក្នុងលោកហើយ គប្បីសិក្សាដើម្បីកម្ចាត់បង់នូវឧបធិនោះចេញ ។

**១១៩- យោ វេ តំ សហតី ជម្មឹ តណ្ហំលោកេ ទុរច្ចយំ សោកាតម្ហា បបតន្តិ ឧទពិន្ទុវ បោក្ខរា ។**

បុគ្គលណាមួយ គ្របសង្កត់តណ្ហាដ៏លាមកនោះ ដែលគេកន្លងបានដោយកម្រក្នុងលោក សេចក្ដីសោកទាំងឡាយរមែងធ្លាក់ចុះចាកបុគ្គលនោះ ដូចជាដំណក់នៃទឹកដែលធ្លាក់ចុះចាកស្លឹកឈូកដូច្នោះ ។

**១២០- រសេសុ គេធំ អករំ អលោលោ អនញ្ញបោសី សបទានចារី កុលេ កុលេ អប្បដិពទ្ធចិត្តោ ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

ភិក្ខុមិនរលោភលន់ មិនធ្វើសេចក្ដីជាប់ចិត្តក្នុងរស មិនចិញ្ចឹមអ្នកដទៃត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក មានចិត្តមិនប្រតិពន្ធក្នុងត្រកូលៗ គប្បីត្រាច់ទៅតែម្នាក់ឯងដូចជាកុយរមាស ។

**១២១- រិត្តស្ស មុនិនោ ចរតោ កាមេសុ អនបេក្ខិនោ ឱឃតិណ្ណស្ស បិហយន្តិ កាមេសុគធិតា បជា ។**

ពួកសត្វជាប់ចិត្តក្នុងកាមទាំងឡាយ រមែងស្រឡាញ់អ្នកប្រាជ្ញដែលប្រព្រឹត្តស្ងប់ស្ងាត់ មិនមានសេចក្ដីអាលោះអាល័យក្នុងកាមដែលឆ្លងឱឃៈបាន ។

**១២២- វិទ្វា ច យោ វេទគូ នរោ ឥធ ភវាភវេ សង្គមិមំ វិសជ្ជ សោ វីតតណ្ហោ អនិឃោ និរាសោ អតារិសោ ជាតិជរន្តិ ព្រូមិ ៚**

នរជនណា ជាអ្នកចេះ ទាំងដល់នូវវេទក្នុងលោកនេះ លះបង់សេចក្តីជំពាក់នេះក្នុងភពតូចធំបានហើយ នរជននោះឈ្មោះថាប្រាសចាកតណ្ហា មិនមានទុក្ខ មិនមានសង្ឃឹម តថាគតពោលថា នរជននោះបានឆ្លងជាតិនឹងជរាហើយ ។

**១២៣- វិវេកញ្ញេវ សិក្ខេថ ឯតទរិយា នមុត្តមំ តេន សេដ្ឋោ ន មញ្ញេថ ស វេ និព្វានសន្តិកេ ៚**

គប្បីសិក្សាវិវេកដែលជាគុនដ៏ខ្ពង់ខ្ពស់នោះ របស់ព្រះអរិយៈទាំងឡាយតែម្យ៉ាង អ្នកណាមិនគប្បីប្រកាន់ខ្លួនថាជាអ្នកប្រសើរ ព្រោះវិវេកនោះ អ្នកនោះឯង ឈ្មោះថាប្រតិបត្តិជិតព្រះនិព្វាន ។

**១២៤- សង្ខេយ្យ សង្ខិតព្វានិ រក្ខេយ្យានាគតំ ភយំ អនាគតភយា ធីរោ ឧភោ លោកេ អវេក្ខតិ ៚**

គប្បីរង្កៀសហេតុដែលគួររង្កៀស គប្បីរក្សាភ័យដែលមិនទាន់មកដល់ ធីរជនរមែងពិចារណាមើលលោកទាំងពីរ ព្រោះខ្លាចអនាគត ។

**១២៥- សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ បរិគ្គហេសុ មុនិ នោបលិត្តោ អព្វុឡ្ហសល្លោ ចរមប្បមត្តោ នាសីសតិ លោកមិមំ បរញ្ច ៚**

បុគ្គលគប្បីឆ្លងឱឃៈបាន ព្រោះកំណត់ដឹងសញ្ញា មុនីមិនជាប់ក្នុងរបស់ដែលគេគប្បីហួងហែង មានសរដកឡើងហើយ ត្រាច់ទៅមិនប្រមាទ រមែងមិនប្រាថ្នាលោកនេះនឹងលោកខាងមុខ ។

**១២៦- សន្តំ តស្ស មនំ ហោតិ សន្តា វចា ច កម្ម ច សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ៚**

បុគ្គលនោះរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ ជាអ្នកស្ងប់រម្ងាប់នឹងធឹង

រមែងមានចិត្តស្ងប់ មានវាចានឹងការងារ (កាយ) ស្ងប់ ។

**១២៧- សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឱ្យដល់ព្រម ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំង៣នេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

**១២៨- សាធុ ធម្មរុចី រាជា សាធុ បញ្ញាណវា នរោ សាធុ មិត្តានមទ្ទុព្ភោ បាបស្សាករណំ សុខំ ។**

ព្រះរាជាគាប់ព្រះទ័យក្នុងធម៌ជាស្តេចល្អ នរជនមានបញ្ញា ជាមនុស្សល្អ អ្នកមិនទ្រុស្តមិត្រជាមិត្រល្អ ការមិនធ្វើបាបនាំមកនូវសេចក្តីសុខ ។

## ១០- បញ្ញាវគ្គ

"ពួកធម៌និយាយពីបញ្ញា"

**១២៩- អទ្ធា ហិ បញ្ញា វ សតំ បសត្ថា កន្តា សិរី ភោគរតា មនុស្សា ញាណញ្ច**

**ពុទ្ធានមតុល្យរូបំ បញ្ញំ ន អច្ចេតិ សិរី កទាចិ ។**

បញ្ញាដែលសប្បុរសសរសើរដោយពិត សិរីជាទីស្រឡាញ់របស់ មនុស្សអ្នកត្រេកអរក្នុងភោគៈ តែញាណរបស់ព្រះពុទ្ធទាំងឡាយថ្លឹងមិនបាន ក្នុងកាលណាៗក៏ដោយ សិរីមិនកន្លងបញ្ញាបានឡើយ ។

**១៣០- គម្ភីរបញ្ញំ មនសាភិចិន្តយំ នច្ចាហិតំ កម្ម ករោតិ លុទ្ទំ កាលាគតំ អត្ថបទំ ន រិញ្ចតិ តថាវិធំ បញ្ញវន្តំ វទន្តិ ។**

អ្នករិះគិតបញ្ញាដ៏ជ្រាលជ្រៅដោយចិត្ត មិនធ្វើកម្មអាក្រក់ ដែលមិនជាប្រយោជ-ន៍ដ៏ក្រៃលែង មិនលះផ្លូវនៃប្រយោជន៍ដែលមកដល់តាមកាល បណ្ឌិតទាំងឡាយ ហៅ

មនុស្សបែបនោះថាអ្នកមានបញ្ញា ។

**១៣១- ទាសោវ បញ្ញស្ស យសស្សិ ពាលោ អត្ថេសុ ជាតេសុ តថាវិធេសុ យំ បណ្ឌិតោ និបុណំ សំវិធេតិ សម្មោហមាបជ្ជតិ តត្ថ ពាលោ ។**

ជនពាលមានយស ក៏ទុកដូចជាទាសៈរបស់អ្នកមានបញ្ញា កាលសេចក្តីត្រូវការបែបនោះកើតឡើង បណ្ឌិតរមែងចាត់ការងារណាដ៏ល្អិតល្អន់បាន តែជនពាលរមែងដល់នូវសេចក្តីវង្វេងក្នុងការងារនោះ ។

**១៣២- បញ្ញវន្តំ តថាវាទឹ សីលេ សុ សុសមាហិតំ ចេតោសមថមនុយុត្តំ តំ វេ វិញ្ញូ បសំសរេ ។**

វិញ្ញូជន រមែងសរសើរអ្នកមានបញ្ញា និយាយពិត តាំងមាំល្អហើយក្នុងសីល ប្រកបដោយធម៌ជាគ្រឿងស្ងប់ចិត្តនោះឯង ។

**១៣៣- បញ្ញា សុតវិនិច្ឆិនី បញ្ញា កិត្តិសិលោកវឌ្ឍនី បញ្ញាសហិតោ នរោ ឥធ អបិ ទុក្ខេសុ សុខានិ វិន្ទតិ ។**

បញ្ញាជាគ្រឿងវិនិច្ឆ័យសុតៈ បញ្ញាជាគ្រឿងចម្រើនកេរ្តិ៍ឈ្មោះនឹងសេចក្តីសរ-សើរ នរជនក្នុងលោកនេះ ប្រកបដោយបញ្ញាហើយ សូម្បីគ្រាមានទុក្ខ គង់បានសេចក្តីសុខ ។

**១៣៤- បញ្ញាយ តិត្តីនំ សេដ្ឋំ ន សោ កាមេហិ តប្បតិ បញ្ញាយ តិត្តំ បុរិសំ តណ្ហា ន កុរុតេ វសំ ។**

បណ្តាសេចក្តីស្អែតទាំងឡាយ សេចក្តីឆ្អែតដោយបញ្ញាប្រសើរបំផុតអ្នកឆ្អែតដោយបញ្ញានោះ រមែងមិនក្តៅក្រហាយដោយកាម តណ្ហារមែងធ្វើអ្នកឆ្អែតដោយបញ្ញាឱ្យលុះក្នុងអំណាចមិនបាន ។

១៣៥- ស បញ្ញវា កាមគុណោ អវេក្ខតិ អនិច្ចតោ ទុក្ខតោ រោគតោ ច ឯវំ វិបស្សី បជហាតិ ឆន្ទំ ទុក្ខេសុ កាមេសុ មហព្ភយេសុ ។

## ១១- បុគ្គលវគ្គ

"ពួកធម៌និយាយពីបុគ្គល"

**១៣៦- អក្កោធនោ អនុបនាហី អមក្ខី សុទ្ធតំ គតោ សម្បន្នទិដ្ឋិ មេធាវី តំ ជញ្ញា អរិយោ ឥតិ ។**

អ្នកណាមិនមានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនលុបគុណគេ ដល់នូវសេចក្តីស្អាត មានទិដ្ឋិបរិបូណ៌ មានបញ្ញា គេគប្បីដឹងថា អ្នកនោះជាអរិយៈ ។

**១៣៧- អក្កោធស្សកុតោកោធោ ទន្តស្ស សមជីវិនោ សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្សតាទិនោ ។**

អ្នកមិនមានសេចក្តីក្រោធ ទូន្មានខ្លួនហើយ ជាអ្នកចិញ្ចឹមជីវិតស្មើផុតស្រឡះព្រោះដឹងដោយប្រពៃ ស្ងប់រម្ងាប់នឹងធឹង នឹងមានសេចក្តីក្រោធមកអំពីណា ។

**១៣៨- អច្ឆិទ្ទវុត្តិំ មេធាវី បញ្ញាសីលសមាហិតំ នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ ។**

អ្នកណា នឹងគួរតិះដៀលមេធាវីបុគ្គល ដែលមានសេចក្តីប្រព្រឹត្តិមិនដាច់ មានបញ្ញាមានសីលមានចិត្តតាំងមាំ ដែលទុកដូចជាឆ្តោនៃមាសជម្ពូនទនោះបាន។

**១៣៩- អនាគតប្បជប្បាយ អតីតស្សានុសោចនា ឯតេន ពាលា សុស្សន្តិ នឡោវ ហរិតោ លុតោ ។**

ការប្រាថ្នារបស់ដែលមិនទាន់មកដល់ នឹងការសោកស្តាយរបស់ដែលកន្លងហួសទៅហើយ ការនោះជាហេតុឱ្យមនុស្សពាលក្រៀមក្រំ ដូចដើមបបោសដែលគេលួសកាត់ដូច្នោះ ។

**១៤០- អនុទ្ធតោ អចបលោ និបកោ សំវុតិន្ទ្រិយោ កល្យាណមិត្តោ មេធាវី ទុក្ខស្សន្តករោសិយា ។**

អ្នកមានបញ្ញា មិនរន្ធត់មិនញាប់ញ័រ មានបញ្ញាជាគ្រឿងរក្សាខ្លួន សង្រួមឥន្ទ្រិយ មានមិត្រល្អ គប្បីជាអ្នកធ្វើនូវទីបំផុតនៃទុក្ខបាន ។

**១៤១- អប្បស្សាទា ទុក្ខា កាមា ឥតិវិញ្ញាយ បណ្ឌិតោ អបិ ទិព្វេសុ កាមេសុ រតឹ សោ នាធិគច្ឆតិ ។**

កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន បណ្ឌិតដឹងដូច្នេះហើយ ទោះបីក្នុងកាមដ៏ជាទិព្យ ក៏លោកមិនទទួលត្រេកអរដែរ ។

១៤២- អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ ន រោ ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។

នរជនណាមិនជឿ(តាមគេថា) ដឹងនូវព្រះនិព្វានដែលអ្វីៗ ធ្វើមិនបាន កាត់តំណបាន មានឱកាសកម្ចាត់បង់ហើយ ទាំងមានបំណងខ្ជាក់ចោលហើយ នរជននោះឯង ហៅថាបុរសឧត្តម ។

១៤៣- អយោគេ យុញ្ជមត្តានំ យោគស្មិញ្ច អយោជយំ អត្ថំ ហិត្វា បិយគ្គាហី បិហេតត្តានុយោគិនំ ។

អ្នកប្រកបខ្លួនក្នុងកិច្ចដែលមិនគួរប្រកប ទាំងមិនប្រកបខ្លួនក្នុងកិច្ចដែលគួរប្រកប លះបង់ប្រយោជន៍ចោល ហើយប្រកាន់សត្វនឹងសង្ខារជាទីស្រឡាញ់ រមែងស្រឡាញ់ចំពោះអ្នកដែលប្រកបខ្លួនរឿយៗ ។

**១៤៤- អសតញ្ច សតញ្ច ញត្វា ធម្មំ អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ ទេវមនុស្សេហិ ច បូជិតោ យោ សោ សង្គជាលមតិច្ច សោ មុនិ ។**

អ្នកណាដឹងធម៌របស់អសប្បុរសនឹងសប្បុរស ទាំងខាងក្នុងនឹងខាងក្រៅ ជាអ្នក

គឺទេវតានឹងមនុស្សទាំងឡាយបូជាហើយក្នុងលោកទាំងពួង អ្នកនោះឯងហៅថាមុនី ព្រោះកន្លងនូវបណ្តាញគឺកិលេសជាគ្រឿងជាប់ជំពាក់បាន ។

**១៤៥- អាកាសេវ បទំ នត្ថិ សមណោ នត្ថិ ពាហិរេ សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ៕**

សមណៈខាងក្រៅមិនមាន សង្ខារទាំងឡាយដែលទៀងទាត់មិនមានសេចក្តីញាប់ញ័ររបស់ព្រះពុទ្ធទាំងឡាយមិនមាន ដូចស្នាមជើងមិនមានក្នុងអាកាសដូច្នោះ។

**១៤៦- ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្សយសោភិវឌ្ឍតិ ៕**

យសរមែងចម្រើនដល់អ្នកមានព្យាយាមរៀសរវៃ១ មានស្មារតី១ មានការងារស្អាត១ ពិចារណាហើយទើបធ្វើ១ ប្រុងប្រយ័ត្ន១ រស់នៅដោយធម៌១ជាអ្នកមិនប្រមាទ១ ។

**១៤៧- ឧត្តមំ ធម្មំ បត្តោ សព្វលោកេ អនត្ថិកោ អាទិត្តាវ ឃរា មុត្តោ មរណស្មឹ ន សោចតិ ៕**

អ្នកបានលុះធម៌ដ៏ឧត្តម មិនមានសេចក្តីត្រូវការក្នុងលោកទាំងពួងចស្រឡះដូចបុគ្គលចេញផុតចាកផ្ទះ ដែលភ្លើងកំពុងឆេះ រមែងមិនសោយសោកក្នុងពេលស្លាប់ ។

**១៤៨- ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ ហំសាវបល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ៕**

ពួកលោកណា មានសតិខំប្រឹងប្រែង ពួកលោកនោះ រមែងមិនត្រេកអរ ក្នុងលំនៅ ពួកលោកនោះ រមែងលះនូវទីអាល័យចេញបាន ដូចពួកហង្ស លះបង់នូវស្រះដូច្នោះ ។

**១៤៩- កាយមនឹ វាចាមុនឹ ចេតោមុនិមនាសវំ មុនឹ មោនេយ្យសម្បន្នំ អាហុ សព្វប្បហាយិនំ ៕**

បណ្ឌិតទាំងឡាយ ហៅអ្នកប្រាជ្ញផ្លូវកាយ ប្រាជ្ញផ្លូវវាចា ប្រាជ្ញផ្លូវចិត្ត មិនមានអាសវៈ បរិបូណ៌ដោយច្បាប់ប្រាជ្ញ លះបង់នូវវត្ថុទាំងពួងបានថាជាមុនី(អ្នកប្រាជ្ញ) ។

**១៥០- កាយសុចឹ វាចាសុចឹ ចេតោសុចិមនាសវំ សុចឹ សោចេយ្យសម្បន្នំ អាហុ និន្ហាតបាបកំ ៕**

បណ្ឌិតទាំងឡាយ ហៅបុគ្គលមានកាយស្អាត មានវាចាស្អាត មានចិត្តស្អាតមិនមានអាសវៈ បរិបូណ៌ដោយសេចក្តីស្អាត បន្សាត់បង់បាបបានថាជាអ្នកស្អាត ។

**១៥១- កោធនោ ឧបនាហីច បាបមក្ខីច យោ នរោ វិបន្នទិដ្ឋិ មាយាវី តំ ជញ្ញា វសលោ ឥតិ ៕**

នរជនណា មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ប្រទ្បាក់ដោយបាប មានទិដ្ឋិខុស ទាំងមានមាយា គេគប្បីដឹងនរជននោះថាជាមនុស្សថោកទាប ។

**១៥២- ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ចណ្ឌាលបុក្កុសា សព្វេវ សោរតា ទន្តា សព្វេ វ បរិនិព្វុតា ៕**

ពួកក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាលនឹងពួកអ្នកចោលសម្រាម អ្នកស្ងប់ស្ងៀមទូន្មានខ្លួនបាន ទាំងអស់គ្នា សុទ្ធតែបរិនិព្វានទាំងអស់ ។

**១៥៣- ចោរំ ហរន្តំ វារេន្តិ ហរន្តោ សមណោ យោ សមណំ បុនប្បុនាយន្តំ អភិនន្ទន្តិ បណ្ឌិតា ៕**

ពួកជនតែងហាមឃាត់ចោរកាលនាំរបស់ទៅ សមណៈ កាលនាំរបស់ទៅជាទីស្រឡាញ់ ពួកបណ្ឌិតរីករាយ នឹងសមណៈដែលមកញយៗ ។

**១៥៤- ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។**

អ្នកឈ្នះគេរមែងប្រសព្វពៀរ អ្នកចាញ់គេរមែងនៅជាទុក្ខ បុគ្គលលះនូវការឈ្នះនឹងការចាញ់ហើយស្ងប់រម្ងាប់ តែងនៅជាសុខ ។

**១៥៥- តស្មាសតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយនា ។**

ព្រោះហេតុនោះ ដំណើរទៅអំពីលោកនេះ របស់សប្បុរសនឹង អសប្បុរសរមែងផ្សេងគ្នា អសប្បុរសតែងទៅកាន់នរក សប្បុរសមានឋានសួគ៌ជាទីប្រព្រឹត្តទៅខាងមុខ។

**១៥៦- តស្មា ហិ ធីរោ ឥធុបដ្ឋិតាសតិ កាមេ ច បាបេ ច អសេវមានោ សហាបិ ទុក្ខេន ជហេយ្យ កាមេ បដិសោតគាមីតិ តមាហុ បុគ្គលំ ។**

ព្រោះហេតុនោះឯង អ្នកប្រាជ្ញមានសតិតាំងមាំក្នុងធម៌វិន័យនេះ មិនសេពកាមនឹងបាបគប្បីលះកាមព្រមទាំងទុក្ខបាន លោកហៅបុគ្គលនោះថាអ្នកទៅច្រាសខ្សែបាន។

**១៥៧- ទុទ្ទទំ ទទមានានំ ទុក្ករំ កម្ម កុព្វតំ អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្វយោ ។**

កាលសប្បុរសឱ្យរបស់ដែលគេលំបាកឱ្យ ធ្វើកម្មដែលគេលំបាកធ្វើ អសប្បុរសរមែងធ្វើតាមមិនបាន ព្រោះថាធម៌របស់សប្បុរសគេដឹងបានដោយលំបាក ។

**១៥៨- នជច្ចាវសលោ ហោតិន ជច្ចា ហោតិ ព្រាហ្មណោ កម្មុនា វសលោ ហោតិ កម្មុនាហោតិ ព្រាហ្មណោ ។**

បុគ្គលមិនមែនជាអ្នកថោកទាបព្រោះជាតិទេ មិនមែនជាអ្នកប្រសើរព្រោះជាតិ

ទេ ជាអ្នកថោកទាបព្រោះកម្ម ជាអ្នកប្រសើរក៏ព្រោះកម្ម ។

**១៥៩- និដ្ឋំ គតោ អសន្តាសី វីតតណ្ហោ អនង្គណោ អច្ឆិន្ទិ ភវសល្លានិ អន្តិមោយំ សមុស្សយោ ។**

បុគ្គលដល់នូវសេចក្តីសម្រេច (អរហត្តផល) មិនមានតក់ស្លុតប្រាសចាកតណ្ហា មិនមានទីទួលគឺកិលេស កាត់កូនសរដែលកាន់ភពបានហើយ រាងកាយនេះឈ្មោះថាមានក្នុងទីបំផុត ។

**១៦០- និល្លោលុបោ និក្កុហោ និប្បិបាសោ និម្មក្ខោ និទ្ធន្តកសាវមោហោ និរាសសោ សព្វលោកេ ភវិត្វា ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

អ្នកមិនល្មោភ មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កម្ចាត់មោហៈ ដូចទឹកអម្ចត់ចេញបាន មិនមានប្រាថ្នា គ្របសង្កត់នូវលោកទាំងអស់ គប្បីត្រាច់ទៅម្នាក់ឯង ដូចកុយរមាសដូច្នោះ ។

**១៦១- បាបំ ន កយិរា វចសា មនសា កាយេន វា កិញ្ចនំ សព្វលោកេ កាមេ បហាយ សតិមា សម្បជានោ ទុក្ខំ ន សេវេថ អនត្ថសញ្ហិតំ ។**

បុគ្គលមិនគួរធ្វើបាបដែលជាគ្រឿងកង្វល់ក្នុងលោកទាំងពួងដោយកាយ វាចា ឬដោយចិត្ត មានសតិសម្បជញ្ញៈ លះកាមទាំងឡាយបានហើយ មិនគប្បីសេពទុក្ខដែលប្រកបដោយរបស់មិនជាប្រយោជន៍ ។

**១៦២- មទនិម្មទនំ សោកនុទំ សំសារបរិមោចនំ សព្វទុក្ខក្ខយំ មគ្គំ សក្កច្ចំ បដិបជ្ជថ ។**

អ្នកទាំងឡាយចូរដើរទៅតាមផ្លូវ ជាទីញាំញីនូវសេចក្តីស្រវឹង ជាទីបន្ទោរបង់នូវសេចក្តីសោក ជាទីដោះសំសារ ជាទីអស់ទៅនៃទុក្ខទាំងពួងដោយគោរពចុះ ។

**១៦៣- មានំ បហាយ សុសមាហិតត្តោ សុចេតសោ សព្វធិ វិប្បមុត្តោ ឯកោ អរញ្ញោ វិហរំ អប្បមត្តោ ស មច្ចុធេយ្យស្ស តរេយ្យបារំ ៕**

អ្នកណាលះមានះ មានខ្លួនតាំងមាំល្អហើយ មានចិត្តល្អ រួចស្រឡះក្នុងទីទាំងពួង នៅក្នុងព្រៃតែម្នាក់ឯង ជាអ្នកមិនប្រមាទ អ្នកនោះគប្បីឆ្លងត្រើយនៃដែនមច្ចុបាន។

**១៦៤- មោសវជ្ជេ ន និយ្យេថ រូបេ ស្នេហំ ន កុព្វយេ មានញ្ច បរិជានេយ្យ សាហសា វិរតោ ចរេ ៕**

បុគ្គលមិនគួរនិយមការពោលពាក្យកុហក មិនគួរធ្វើសេចក្ដីស្នេហាក្នុងរូប តែគួរកំណត់ដឹងមានះ គួរប្រព្រឹត្តវៀរចាកអំពើសាហ័ស ។

**១៦៥- មានេន វញ្ចិតាសេ សង្ខារេសុ សង្កិលិស្សមានាសេ លាភាលាភេន មថិតា សមាធឹ នាធិគច្ឆន្តិ ៕**

អ្នកត្រូវមានះបញ្ឆោត សៅហ្មងព្រោះសង្ខារទាំងឡាយ ត្រូវលាភនឹងសេចក្ដីវិនាសលាភញាំញី រមែងមិនបានសមាធិ ។

**១៦៦- យម្ហិ សច្ចញ្ច ធម្មោច អហឹសា សញ្ញមោ ទមោ ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ៕**

សច្ចៈ១ធម្ម១ អហឹសា១ សញ្ញមៈ១ ទមៈ១ មានក្នុងបុគ្គលណា បុគ្គលនោះឯងលោកហៅថា អ្នកបញ្ញា មានមន្ទិលខ្ជាក់ចោលហើយបុគ្គលនោះលោកហៅថា ថេរៈ។

**១៦៧- យទា ទុក្ខំ ជរាមរណន្តិ បណ្ឌិតោ អវិទ្ទសុ យត្ថ សិតា បុថុជ្ជនា ទុក្ខំ បរិញ្ញាយ សតោ វ ឈាយតិ តតោ រតឹ បរមតរំ ន វិន្ទតិ ៕**

កាលណា បណ្ឌិតដឹងថា ជរានឹងមរណៈជាទុក្ខ កំណត់ដឹងទុក្ខដែលបុថុជ្ជនអាស្រ័យហើយមិនដឹង ក៏មានស្មារតីពិនិត្យមើល កាលនោះមិនបាននូវសេចក្ដីត្រេកអរដ៏ក្រៃលែងជាងនោះ ។

**១៦៨- យស្សរាគោ ច ទោសោ ច មនោ មក្ខោចបាតិតោ សាសបោរិវ អារគ្គា តមហំ ព្រូមិព្រាហ្មណំ ៕**

រាគៈ ទោសៈ មានៈនឹងមក្ខៈ ដែលអ្នកណាទម្លាក់ចោលហើយដូចគ្រាប់ស្ពៃ ដែលធ្លាក់ចាកចុងដែកស្រួច តថាគតហៅអ្នកនោះថាជាព្រាហ្មណ៍ ។

**១៦៩- យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី អមំតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ៕**

សេចក្តីអាល័យរបស់អ្នកណាមិនមាន អ្នកណាដឹងហើយមិនមាន សេចក្តីសង្ស័-យ តថាគតហៅអ្នកដែលចុះស៊ប់ភាន់អមតៈសម្រេចប្រយោជន៍ ដោយលំដាប់នោះ ថាជាព្រាហ្មណ៍ ។

**១៧០- យេ កេចិ កាមេសុ អសញ្ញតា ជនា អវីតរាគា ឥធ កាមភោគិនោ បុនប្បុនំ ជាតិជរូបគា ហិ តេ តណ្ហាធិបន្នា អនុសោតគាមិនោ ៕**

ពួកជនណាមួយ មិនសង្រួមក្នុងកាម មិនទាន់ប្រាសចាករាគៈ ជាអ្នកបរិភោគកាមក្នុងលោកនេះ ពួកជននោះ ត្រូវតណ្ហាគ្របសង្កត់ទៅតាមខ្សែ (តណ្ហា) ជាអ្នកចូលទៅកាន់ជាតិនឹងជរាញយៗ ។

**១៧១- យេ ច ខោ ពាលា ទុម្មេធា ទុម្មន្តី មោហបារុតា តាទិសា តត្ថ វជ្ជន្តិ មារក្ខិត្តស្មិ ពន្ធនេ ៕**

ពួកជនណាល្ងង់ខ្លៅ ឥតប្រាជ្ញា មានគំនិតអាក្រក់ត្រូវមោហៈហ៊ុមព័ទ្ធ ពួកជនបែបនោះរមែងជាប់ចំណងដែលមារបោះទៅក្នុងទីនោះ ។

**១៧២- យេ ច សីលេន សម្បន្នា បញ្ញាយូ ប សមេ រតា អារកា វិរតា ធីរា ន ហោន្តិ បរបត្តិយា ៕**

ពួកធីរជនណា បរិបូណ៌ដោយសីល ត្រេកអរក្នុងសេចក្តីស្ងប់ដោយបញ្ញា ពួក

ធីរជននោះ ជាអ្នកវៀរឆ្ងាយចាកសេចក្តីអាក្រក់ហើយ មិនមានការជឿអ្នកដទៃ។

**១៧៣- យេ ឈានបសុតា ធីរា នេក្ខម្មូបសមេ រតា ទេវាបិ តេសំ បិហយន្តិ សម្ពុទ្ធានំ សតីមតំ ។**

ពួកធីរជនណា ខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងសេចក្តីស្ងប់ដែលកើតអំពីនេក្ខម្ម សូម្បីទេវតាទាំងឡាយ ក៏ស្រឡាញ់ចំពោះធីរជននោះដែលត្រាស់ដឹងល្អ មានស្មារតី ។

**១៧៤- យេសំ រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា តាទី តត្ថ ន វជ្ជន្តិ ឆិន្នសុត្តា អពន្ធនា ។**

រាគៈ ទោសៈ នឹងអវិជ្ជា ដែលអ្នកណារួចហើយ អ្នកនោះជាអ្នកនឹងធឹង មានខ្សែដាច់ហើយ មិនមានគ្រឿងចង រមែងមិនជាប់ក្នុងទីនោះ ។

**១៧៥- យោ ច គុត្តេន ចិត្តេន សុណាតិ ជិនសាសនំ ខេបេត្វា អាសវេ សព្វេ សច្ឆិកត្វា អកុប្បតំ បប្បុយ្យ បរមំ សន្តី បរិនិព្វាតិ អនាសវោ ។**

អ្នកណាមានចិត្តគ្រប់គ្រងហើយ ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះជិន អ្នកនោះឈ្មោះថាញ៉ាំងអាសវៈទាំងពួងឱ្យអស់ទៅ ធ្វើឱ្យជាក់ច្បាស់នូវអកុប្បធម៌ គប្បីលុះនូវសេចក្តីស្ងប់ដ៏ក្រៃលែង មិនមានអាសវៈរមែងរលត់ផុត ។

**១៧៦- យោ តេសុ គុត្តោ វិទិតិន្ទ្រិយោ ចរេ ធម្មេ ឋិតោ អាជ្ជវមទ្ទវេ រតោ សង្គាតិគោ សព្វទុក្ខប្បហីនោ ន លិម្បតិ ទិដ្ឋសុតេសុ ធីរោ ។**

ធីរជនណាគ្រប់គ្រងឥន្ទ្រិយទាំងនោះ ដឹងច្បាស់ឥន្ទ្រិយទាំង៦ គប្បីត្រាច់ទៅស្ថិតនៅក្នុងធម៌ ត្រេកអរក្នុងសេចក្តីត្រង់នឹងសេចក្តីទន់ភ្លន់ កន្លងកិលេសជាគ្រឿងជាប់ជំពាក់ លះទុក្ខទាំងអស់បាន ធីរជននោះរមែងមិនជាប់ក្នុងរបស់ដែលបានឃើញនឹងរបស់ដែលបានឮ ។

**១៧៧- រោសកោ កទរិយោ ច បាបិច្ឆោ មច្ឆរី សឋោ អហិរិកោ អនោត្តប្បី តំ ជញ្ញា វសលោ ឥតិ ។**

អ្នកណាជាមនុស្សខឹងប្រឡោត កន្ទ្រីសប្ញស្សា ប្រាថ្នាលាមកមានសេចក្ដីកំណាញ់ អួតអាងមិនខ្មាសបាប មិនខ្លាចបាប គេគប្បីដឹងអ្នកនោះថាជាមនុស្សថោកទាប ។

**១៧៨- លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតិ អវិរុទ្ធោ ច តណ្ហាយ រសេ ច នានុគិជ្ឈតិ ។**

បណ្ឌិតមិនសិក្សាព្រោះប្រាថ្នាលាភ មិនកម្រើកព្រោះវិនាសលាភ មិនត្រេកអរខេខឹងព្រោះតណ្ហា ទាំងមិនជាប់ស្អិតក្នុងរស ។

១៧៩- សង្ខាយ លោកស្មឹ បរោបរានិ យ ស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ សន្តោ វិធូមោ អនិឃោ និរាសោ អតារិ សោ ជាតិជរន្តិ ព្រូមិ ។

អ្នកណាពិចារណាឃើញ សភាវធម៌ទាំងទាបទាំងខ្ពស់ក្នុងលោកហើយមិនមានសេចក្ដីញាប់ញ័រក្នុងអារម្មណ៍ណាមួយក្នុងលោក តថាគតពោលថា អ្នកនោះជាអ្នកស្ងប់ ប្រាសចាកផ្សែង មិនមានទុក្ខ មិនមានចំណង់ ឆ្លងជាតិជរាបាន ។

**១៨០- សព្វទា វេ សុខំ សេតិ ព្រាហ្មណោ បរិនិព្វុតោ យោ ន លិម្បតិ កាមេសុ សីតិភូតោ និរូបធិ ។**

អ្នកណាជាអ្នកត្រជាក់ មិនមានឧបធិ មិនជាប់ក្នុងកាម អ្នកនោះឈ្មោះថាព្រាហ្មណ៍ ជាអ្នករលត់ផុត រមែងនៅជាសុខសព្វកាល ។

**១៨១- សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

អ្នកណាមិនមានសេចក្ដីប្រកាន់ថារបស់អញក្នុងនាមរូបដោយប្រការ ទាំងពួង ទាំងមិនសោយសោកព្រោះនាមរូបដែលមិនមាន អ្នកនោះឯងលោកហៅថា ភិក្ខុ ។

**១៨២- សព្វា អាសត្តិយោ ឆេត្វា វិនេយ្យ ហទយេ ទរំ ឧបសន្តោ សុខំ សេតិ សន្តឹ បប្បុយ្យចេតសោ ៕**

អ្នកណាគប្បីកាត់សេចក្ដីជាប់ចំពាក់ទាំងពួង ហើយបន្ទោរបង់សេចក្ដីក្រវល់ក្រវាយចិត្តបាន អ្នកនោះគប្បីដល់សេចក្ដីស្ងប់ចិត្ត ជាអ្នកស្ងប់រម្ងាប់ តែងនៅជាសុខ។

**១៨៣- សព្វេសុ កាមេសុ យោ វីតរាគោ អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ សញ្ញាវិមោក្ខេ បរមេធិមុត្តោ តិដ្ឋេយ្យ សោ តត្ថ អនានុយាយី ៕**

អ្នកណាប្រាសចាកតម្រេកក្នុងកាមទាំងពួង លះបង់ឈានដទៃបានហើយ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ អ្នកនោះគប្បីស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ មិនមានឃ្លាតទៅ ។

**១៨៤- ស វីតរាគោ ស វិនេយ្យ ទោសំ មេត្តចិត្តំ ភាវេយ្យ អប្បមាណំ សព្វេសុ ភូតេសុ និធាយ ទណ្ឌំ អនិន្ទិតោ ព្រហ្មមុបេតិ ឋានំ ៕**

អ្នកប្រាសចាករាគៈ ទាំងកម្ចាត់ទោសៈបានហើយនោះ គប្បីចម្រើនមេត្តាចិត្តមិនមានប្រមាណ អ្នកនោះឈប់ដាក់អាជ្ញាក្នុងសត្វទាំងពួងហើយ មិនត្រូវគេតិះដៀលរមែងចូលទៅកាន់ស្ថានដ៏ប្រសើរ ។

**១៨៥- សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ តំ ព្រូមិ មហាបុរិសោតិ សោ ឥធ សិព្វនិមច្ចគា ៕**

គេដឹងនូវទីបំផុតទាំងពីរហើយ រមែងមិនជាប់ត្រង់កណ្ដាល ព្រោះការដឹងតថាគតហៅគេថា មហាបុរស ព្រោះថាគេកន្លងតណ្ហាជាគ្រឿងចាក់ស្រេះចិត្តក្នុងលោកនេះបាន ។

**១៨៦- សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេ តស្មា មុនយោ បរិគ្គហំ ហិត្វា អចរឹសុ ខេមទស្សិនោ ៕**

ពួកជនជាប់ក្នុងអារម្មណ៍ដែលគេប្រកាន់ថា របស់អញ រមែងលះបង់សេចក្តីសោក ខ្សឹកខ្សួល នឹងសេចក្តីកំណាញ់មិនបាន ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ឃើញធម៌ដ៏ក្សេម ទើបលះសេចក្តីប្រកាន់ទៅបាន ។

**១៨៧- សោចតិ បុត្តេហិ បុត្តិមា គោមិកោ គោហិ តថេវ សោចតិ ឧបធីហិ នរស្ស សោចនា ន ហិ សោ សោចតិ យោ និរូបធិ ។**

អ្នកមានកូនរមែងសោយសោកព្រោះកូន អ្នកមានគោរមែងសោយសោកព្រោះគោដូចគ្នា នរជនមានសេចក្តីសោយសោកព្រោះឧបធិ អ្នកណាមិនមានឧបធិ អ្នកនោះមិនសោយសោកឡើយ ។

## ១២- មច្ចុវគ្គ

"ពួកធម៌និយាយអំពីមច្ចុ"

**១៨៨- អច្ចេន្តិ កាលា តរយន្តិ រត្តិយោ វយោគុណា អនុបុព្វំ ជហន្តិ ឯតំ ភយំ មរណេ បេក្ខមានោ បុញ្ញានិ កយិរាថ សុខាវហានិ ។**

កាលទាំងឡាយតែងកន្លងទៅ រាត្រីទាំងឡាយតែរំលងទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះលំដាប់ទៅ បុគ្គលកាលសំឡឹងនូវភ័យក្នុងមរណៈនុ៎ះ គប្បីធ្វើបុណ្យទាំងឡាយ ដែលនាំសុខមកឱ្យ ។

**១៨៩- ផលានមិវ បក្កានំ បាតោ បតនតោ ភយំ ឯវំ ជាតាន មច្ចានំ និច្ចំ មរណតោ ភយំ ។**

ភ័យអំពីសេចក្តីស្លាប់ទៀងតែមានដល់ពួកសត្វដែលកើតហើយ ដូចជាភ័យអំពីការជ្រុះក្នុងវេលាព្រឹកមានដល់ផ្លែឈើទុំ ដូច្នោះ ។

**១៩០- រូបធាតុបរិញ្ញាយ អរូបេសុ អសណ្ឋិតា និរោធេ យេ វិមុច្ចន្តិ តេ ជនា មច្ចុហាយិនោ ។**

ពួកជនណាកំណត់ដឹងរូបធាតុ មិនតាំងនៅក្នុងអរូបធាតុ រមែងរួចផុតក្នុងនិរោធធាតុ ពួកជននោះឈ្មោះថាជាអ្នកលះមច្ចុបាន ។

## ១៣- វាចាវគ្គ

"ពួកធម៌និយាយអំពីវាចា"

**១៩១- អកក្កសំ វិញ្ញាបនិំ គិរំ សច្ចំ ឧទីរយេ យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

អ្នកណា គប្បីពោលពាក្យដែលមិនជាហេតុឱ្យអ្នកណាៗ ទាស់ចិត្តមិនទ្រគោះបោះបោក ជាគ្រឿងឱ្យគេដឹងសេចក្តីបាន ទាំងជាពាក្យពិតតថាគតហៅអ្នកនោះថាជាព្រាហ្មណ៍ ។

**១៩២- អក្កោធនោ អសន្តាសី អវិកត្ថី អកុក្កុចោ មន្តាភាណី អនុទ្ធតោ ស វេ វាចាយតោ មុនិ ។**

អ្នកណា មិនក្រោធមិនតក់ស្លុត មិនអួតអាង មិនរង្កៀស ប្រសប់និយាយមិនរាយមាយ អ្នកនោះឯងឈ្មោះថា មុនី មានវាចាសង្រួមហើយ ។

**១៩៣- អពទ្ធា តត្ថ ពជ្ឈន្តិ យត្ថ ពាលា បភាសរេ ពទ្ធាបិ តត្ថ មុច្ចន្តិ យត្ថ ធីរា បភាសរេ ។**

ពួកពាល រមែងពោលក្នុងរឿងណា ដែលគេមិនចង ក៏គង់ជាប់ក្នុងរឿងនោះ ពួកអ្នកមានប្រាជ្ញារមែងពោលក្នុងរឿងណា សូម្បីគេចងក៏គង់ដោះរួចក្នុងរឿងនោះ ។

**១៩៤- បរស្ស វា អត្តនោ វាបិ ហេតុ ន ភាសតិ អលិកំ ភូរិបញ្ញោ សោ បូជិតោ ហោតិ សភាយ មជ្ឈេ មច្ចាបិ សោ សុគ្គតិគាមិ ហោតិ ។**

អ្នកមានប្រាជ្ញាដូចផែនដី មិននិយាយពាក្យកុហក ព្រោះហេតុនៃអ្នកដទៃឬខ្លួនឯង អ្នកនោះ រមែងមានគេបូជាក្នុងកណ្តាលនៃទីជំនុំ លុះខាងក្រោយមក អ្នកនោះ

រមែងទៅកាន់សុគតិ ។

**១៩៥- យំ ពុទ្ធោ ភាសតី វាចំ ខេមំ និព្វានបត្តិយា ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមា ៕**

ព្រះពុទ្ធត្រាស់វាចាណា ជាពាក្យក្សេម ដើម្បីលុះព្រះនិព្វានដើម្បីធ្វើនូវទីបំផុត នៃទុក្ខ ព្រះវាចានោះឯងខ្ពង់ខ្ពស់ជាងវាចាទាំងឡាយ ។

**១៩៦- សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ សច្ចេ អត្ថេ ច ធម្មេ ច អហុ សន្តោ បតិដ្ឋិតា៕**

ពាក្យសច្ចៈហ្នឹងឯង ជាវាចាមិនចេះស្លាប់ ធម៌នេះជាធម៌ជាន់ចាស់សប្បុរសទាំង ឡាយ ជាអ្នកតាំងមាំក្នុងពាក្យសច្ចៈដែលជាអត្ថជាធម៌ ។

## ១៤- វីរិយវគ្គ

"ពួកធម៌និយាយពីព្យាយាម"

**១៩៧- កោសជ្ជំ ភយតោ ទិស្វា វីរិយារម្ភញ្ច ខេមតោ អារទ្ធវីរិយា ហោថ ឯសា ពុទ្ធានុសាសនី ៕**

អ្នកទាំងឡាយ ឃើញសេចក្តីខ្ជិលថាជាភ័យ ទាំងឃើញការប្រារព្ធសេចក្តីព្យាយាមថាជាធម៌ក្សេម (ចាកភ័យ) ចូរប្រារព្ធសេចក្តីព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

**១៩៨- តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា បដិបន្នា បមោក្ខន្តិ ឈាយិនោ មារពន្ធនា ៕**

អ្នកទាំងឡាយ ត្រូវធ្វើសេចក្តីព្យាយាម ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ អ្នកមានប្រក្រតី ពិនិត្យប្រតិបត្តិហើយ ទើបរួចចាកចំណងរបស់មារបាន ។

**១៩៩- និទ្ទំ តន្ទឹ វិចិម្ហិតំ អរតី ភត្តសម្មទំ វីរិយេន នំ បណាមេត្វា អរិយមគ្គោ វិសុជ្ឈតិ ។**

ព្រះអរិយមគ្គ រមែងបរិសុទ្ធ ព្រោះកំចាត់នូវសេចក្តីលក់ទ្រមក់ ខ្ជិលមិនពត់កាយ មិនត្រេកអរទាំងស្រវឹងក្នុងភត្តនោះបាន ដោយសេចក្តីព្យាយាម ។

**២០០- យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ ឯកាហំ ជីវិតំ សេយ្យោ វីរិយំអារភតោ ទឡ្ហំ ។**

អ្នកណាមួយខ្ជិលច្រអូស មានព្យាយាមថោកទាប គប្បីរស់នៅអស់រយនៃឆ្នាំ ពុំប្រសើរស្មើនឹងការរស់នៅមួយថ្ងៃ នៃអ្នកដែលប្រារព្ធនូវព្យាយាមមាំ ។

**២០១- សទ្ធោ សីលសម្បន្នោ បញ្ញវា សុសមាហិតោ អារទ្ធវីរិយោ បហិតត្តោ ឱឃំ តរតិ ទុត្តរំ ។**

អ្នកបរិបូណ៌ដោយសីល មានបញ្ញា មានចិត្តតាំងមាំល្អហើយប្រារព្ធសេចក្តីព្យាយាម មានចិត្តស្លុងទៅគ្រប់កាល រមែងឆ្លងឱឃៈ ដែលគេឆ្លងដោយកម្របាន ។

## ១៥- សាមគ្គីវគ្គ

"ពួកធម៌និយាយពីសាមគ្គី"

**២០២- វិវាទំ ភយតោ ទិស្វា អវិវាទញ្ច ខេមតោ សមគ្គា សខិលា ហោថ ឯសា ពុទ្ធានុសាសនី ។**

អ្នកទាំងឡាយ ឃើញសេចក្តីទាស់ទែង ថាជាភ័យ ទាំងឃើញសេចក្តីមិនទាស់ទែង ថាជាធម៌ក្សេម (ចាកភ័យ) ចូរជាអ្នកព្រមព្រៀងគ្នាមាន សេចក្តីស្រស់ស្រាយរកគ្នាចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

**២០៣- សាមគ្គ្យមេវ សិក្ខេថ ពុទ្ធេហេតំ បសំសិតំ សាមគ្គ្យរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ ។**

គប្បីសិក្សាសាមគ្គីតែម្យ៉ាង សាមគ្គីនោះ ព្រះពុទ្ធទាំងឡាយទ្រង់សរសើរហើយ អ្នកត្រេកអរក្នុងសាមគ្គី ស្ថិតនៅក្នុងធម៌ រមែងមិនឃ្លាតអំពីធម៌ដ៏ក្សេមចាកយោគៈ ។

**២០៤- សុខា សង្ឃស្ស សាមគ្គី សមគ្គានញ្ចានុគ្គហោ សមគ្គរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ ។**

សាមគ្គីរបស់ពួកនាំមកនូវសុខ ទាំងការអនុគ្រោះ របស់អ្នកព្រមព្រៀងគ្នាក៏នាំមកនូវសុខ អ្នកត្រេកអរក្នុងបុគ្គលអ្នកព្រមព្រៀងគ្នា ស្ថិតនៅក្នុងធម៌ រមែងមិនឃ្លាតអំពីធម៌ដ៏ក្សេមចាកយោគៈ ។

## ១៦- សីលវគ្គ

"ពួកធម៌និយាយពីសីល"

**២០៥- ខុន្នឡស្ស បមត្តស្ស ពាហិរាសស្ស ភិក្ខុនោ សីលំ សមាធិ បញ្ញា ច បារិបូរី ន គច្ឆតិ ។**

កាលភិក្ខុ ដំឡើងមានៈដូចដើមបបុស ប្រមាទហើយ មានសេចក្ដីប្រាថ្នាខាងក្រៅ សីល សមាធិ នឹងបញ្ញារមែងមិនដល់នូវសេចក្ដីបរិបូណ៌ ។

**២០៦- តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

មារមិនបាននូវផ្លូវ របស់លោកអ្នកមានសីលដ៏បរិបូណ៌ មានប្រក្រតីនៅដោយសេចក្ដីមិនប្រមាទ ផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ។

**២០៧- សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។**

សីលជាកម្លាំង ឥតមានអ្វីផ្ទឹមបាន សីលជាអាវុធដ៏ខ្ពង់ខ្ពស់ សីលជាគ្រឿងប្រដាប់ដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។

**២០៨- សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោជយំ ។**

សីលហ្នឹងឯង ដ៏លើសក្នុងលោកនេះ ចំណែកអ្នកមានបញ្ញាជាអ្នកខ្ពង់ខ្ពស់ សេចក្តីឈ្នះក្នុងពួកមនុស្សនឹងទេវតា រមែងមានព្រោះសីលនឹងបញ្ញា ។

**២០៩- សីលំ សម្ពលមេវគ្គំ សីលំ បាថេយ្យមុត្តមំ សីលំសេដ្ឋោ អតិវាហោ យេន វាតិ ទិសោទិសំ ។**

សីលជាធម្មជាតមានកម្លាំងដ៏លើសលប់ សីលជាស្បៀងដ៏ខ្ពស់ខ្ពស់សីលជាគ្រឿងនាំទៅដ៏ប្រសើរ ដែលខ្ចរខ្ចាយទៅគ្រប់ទិស ។

**២១០- សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ សីលំ វិលេបនំ សេដ្ឋំ យេនវាតិ ទិសោទិសំ ។**

សីលជាស្ពានដ៏មានស័ក្តិធំ សីលជាក្លិនដែលមិនមានក្លិនដទៃលើសជាង សីលជាគ្រឿងលាបលនយ៉ាងប្រសើរដែលខ្ចរខ្ចាយទៅគ្រប់ទិស ។

១៧- សេវនាវគ្គ

"ពួកធម៌និយាយពីការសេពគប់"

**២១១- ឧទ្ធតោ ចបលោ ភិក្ខុ មិត្តេ អាគម្ម បាបកេ សំសីទតិ មហោឃស្មឹ ឧម្មិយា បដិកុជ្ជិតោ ។**

ភិក្ខុអ្នករាយមាយឃ្លេងឃ្លោង អាស្រ័យបាបមិត្រ (អត់ធន់ចំពោះពាក្យប្រៀនប្រដៅមិនបាន) ត្រូវរលកបោកផ្ងប់ហើយរមែងលិចចុះក្នុងអន្លង់ធំ ។

**២១២- ធម្មកាមោ សុតាធារោ ភវេយ្យ បរិបុច្ឆកោ សក្កច្ចំ បយិរុបាសេយ្យ សីលវន្តេ ពហុស្សុតេ ។**

គប្បីជាអ្នកស្រឡាញ់ធម៌ ទ្រទ្រង់នូវសុតៈ ជាអ្នកសាកសួរ គួរចូលទៅអង្គុយជិត

លោកអ្នកមានសីលទាំងជាពហុស្សូត្រ ដោយសេចក្តីគោរព ។

**២១៣- និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

ឃើញបណ្ឌិតបែបណា អ្នកមានប្រក្រតីចង្អុលប្រាប់ទោសដូចអ្នកចង្អុលប្រាប់កំណប់ទ្រព្យឱ្យ អ្នកមានប្រក្រតីពោលផ្ចាញផ្ចាល់ មានបញ្ញាគប្បីគប់រក បណ្ឌិតបែបនោះ កាលបើគប់រកបណ្ឌិតបែបនោះ រមែងប្រសើរបំផុតមិនថោកទាបឡើយ ។

**២១៤- និហីយតិ បុរិសោ និហីនសេវី ន ច ហាយេថ កទាចិ តុល្យសេវី សេដ្ឋមុបនមំ ឧទេតិ ខិប្បំ តស្មា អត្តនោ ឧត្តរឹ ភជេថ ។**

ក្នុងកាលណាៗ បុរសអ្នកសេពគប់នឹងបុគ្គលថោកទាបរមែងថោកទាប អ្នកសេពគប់នឹងបុគ្គលស្មើគ្នា រមែងមិនសាបសូន្យឡើយ អ្នកឱនលំទោនចំពោះបុគ្គលប្រសើររមែងខ្ពស់ឡើងឆាប់ ហេតុនោះគួរគប់រកបុគ្គលដែលខ្ពស់ជាងខ្លួន ។

**២១៥- បសន្នមេវ សេវេយ្យ អប្បសន្នំ វិវជ្ជយេ បសន្នំ បយិរុបាសេយ្យ រហទំវុទកត្ថិយោ ។**

បុគ្គលគួរសេពគប់នូវអ្នកដែលជ្រះថ្លាតែម្យ៉ាង គួរវៀរអ្នកដែលមិនជ្រះថ្លា គួរចូលទៅអង្គុយជិតអ្នកដែលជ្រះថ្លាដូចគេត្រូវការទឹក ចូលទៅរកស្រះទឹកដូច្នោះដែរ ។

**២១៦- បិសុណេន ច កោធនេន មច្ឆរិនា ច វិភូតិនន្ទិនា សខិតំ ន ករេយ្យ បណ្ឌិតោ បាបោ កាបុរិសេន សង្គមោ ។**

បណ្ឌិតមិនគប្បីធ្វើសខិភាពនឹងជនដែលពោលពាក្យញុះញង់ ជនក្រោធជនកំណាញ់ នឹងជនដែលភ្លើតភើនក្នុងសម្បត្តិ ព្រោះថាការសមាគមនឹងមនុស្សអាក្រក់ជាសេចក្តីថោកទាប ។

**២១៧- ភជេ ភជន្តំ បុរិសំ អភជន្តំ ន ភជ្ជយេ អសប្បុរិសធម្មោ សោ យោ ភជន្តំ ន ភជ្ជតិ ៕**

គួរគប់រកបុរសដែលគប់រកខ្លួន មិនគួរគប់រកបុរសដែលមិនគប់រកខ្លួន អ្នកណាមិនគប់រកបុរសដែលគប់រកខ្លួន អ្នកនោះ ឈ្មោះថាមិនមានសប្បុរិសធម៌ ។

**២១៨- សព្ភិបវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ ៕**

គប្បីសេពគប់នឹងពួកសប្បុរស គប្បីធ្វើសេចក្តីស្និទ្ធស្នាលនឹងពួកសប្បុរស លុះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរសហើយ រមែងរួចស្រឡះចាកទុក្ខទាំងពួង ។

**ចប់**